ឆ្នាំទី៥ លេខ ៥១ ខែ មីនា ឆ្នាំ២០១៧

ព្រឹត្តិបត្រ

# កៅស៊ូធម្មជាតិ

# Natural Rubber Bulletin

ផ្សាយចេញពី អគ្គនាយកដ្ឋានកៅស៊ូ

ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០



## នាយកបណ្ណាធិការ

- ឯកឧត្តម **ប៉ុល សុផា**

## គណៈកម្មាធិការបណ្ណាធិការ

- លោក **ឃុន កក្កដា** ប្រធាន
- លោក **ឃួន ផល្លា** អនុប្រធាន
- លោក **ហ៊ន សាផន** អនុប្រធាន
- លោក **គុយ ភក្តី** សមាជិកអចិន្ត្រៃយ៍
- លោក **ព្រៃ សុភាព** សមាជិក
- លោក **លួង សុខខេង** សមាជិក
- លោក **សុក សារុំ** សមាជិក
- លោក **អៀង ស៊ីថា** សមាជិក
- លោក **កែវ សំអុន** សមាជិក

## ការីកុំព្យូទ័រ

- លោក **យឹម ដារ៉ា**
- កញ្ញា **ស៊ឹម មុំ**
- លោក **ជុំ មៅ**

## ការីទំនាក់ទំនងនិងបោះពុម្ព

- លោក **គុយ ភក្តី**
- E-mail phokpheakdey@yahoo.com
- Tel: ០១៦ ២៩៣ ៤២៣

## Editor-in-chief

- H.E. Pol Shopha

## Editorial Board

- Mr. Khun Kakada Director
- Mr. Khuon Phalla Vice Director
- Mr. Horn Saphan Vice Director
- Mr. Kuy Pheakdey Permanent Member
- Mr. Prey Sopheap Member
- Mr. Loung Sokheng Member
- Mr. Sok Sarom Member
- Mr. Ieng Sitha Member
- Mr. Keo Somonn Member

## Computer Operator

- Mr. Yim Dara
- Miss. Sim Mom
- Mr. Chum Mouv

## Contact & Publication

- Mr. Kuy Pheakdey
- E-mail: phokpheakdey@yahoo.com
- Tel: 016 293 423

| មាតិកា | ទំព័រ |
|---|---|
| ❖ បទវិចារណកថា | ១ |
| **ព័ត៌មានក្នុងប្រទេស** | |
| ❖ អនុក្រឹត្យស្តីពី «ការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ | ៣ |
| ❖ ពិធីអបអរសាទរ ទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១០៦ | ៥ |
| ❖ ឯកឧត្តមប្រតិភូ បានអញ្ជើញចុះបើកវគ្គបណ្តុះ បណ្តាលស្តីពី «ការបើកមុខចៀរជ័រដំបូងនិងបទដ្ឋានបច្ចេកទេសចៀរជ័រ» នៅខេត្តសៀមរាបនិងឧត្តរមានជ័យ | ៦ |
| ❖ វគ្គផ្សព្វផ្សាយបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS ដល់សហគមន៍កៅស៊ូគ្រួសារ | ៨ |
| **ព័ត៌មានអន្តរជាតិ** | |
| ❖ រដ្ឋាភិបាលស្រីលង្កាសម្រេចផ្តល់ថវិកា ១,៥ពាន់លានរូពី សម្រាប់ជួយឧបត្ថមជាជី ដល់កសិករដាំដំណាំតែ ដូង និងកសិករកៅស៊ូគ្រួសារ | ១០ |
| ❖ រដ្ឋ Sarawak ត្រូវការផែនការមេ ដើម្បីពង្រឹងឧស្សាហកម្មកៅស៊ូ | ១០ |
| ❖ ក្រុមហ៊ុនលីងឡុងសម្លឹងមើលការជម្រុញផលិតកម្ម | ១២ |
| ❖ ឥណ្ឌូនេស៊ីៈ បារាំងនឹង អភិវឌ្ឍន៍កៅស៊ូប្រកបដោយនិរន្តរភាព | ១២ |
| **ទំព័រស្រាវជ្រាវ** | |
| ❖ ចលនការរបស់សារធាតុគីមីដែលប្រើប្រាស់ក្នុងការកែច្នៃជ័រកៅស៊ូធម្មជាតិ (តចប់) | ១៤ |
| ❖ ការគ្រប់គ្រងលើការចៀរជ័រកៅស៊ូ | ១៦ |
| **តម្លៃនិងស្ថិតិកៅស៊ូធម្មជាតិ** | |
| ❖ តារាងទី១៖ តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅតាមបណ្តាស្រុកប្រចាំសប្តាហ៍ ខែមីនា ឆ្នាំ២០១៧ | ២៤ |
| ❖ តារាងទី២៖ តម្លៃកៅស៊ូនៅទីផ្សារប្រទេសថៃ ប្រចាំខែមីនា ឆ្នាំ២០១៧ | ២៥ |
| ❖ តារាងទី៣៖ តម្លៃកៅស៊ូស្តង់ដាម៉ាឡេស៊ី SMR/FOB ប្រចាំខែមីនា ឆ្នាំ២០១៧ | ២៦ |
| ❖ តារាងទី៤៖ តម្លៃកៅស៊ូធម្មជាតិចេញដោយ Association of Natural Rubber Producing Countries ប្រចាំខែមីនា ឆ្នាំ២០១៧ | ២៧ |
| ❖ តារាងទី៥៖ តម្លៃកៅស៊ូធម្មជាតិប្រចាំសប្តាហ៍ជាមធ្យម តាមបណ្តាប្រទេសផលិតកៅស៊ូ | ២៨ |
| ❖ តារាងទី៦៖ ការនាំចេញកៅស៊ូធម្មជាតិរបស់ប្រទេសជាសមាជិកសមាគម ANRPC | ២៨ |
| ❖ តារាងទី៧៖ តម្លៃកៅស៊ូសន្លឹកលេខ៣ (RSS3) នៅលើទីផ្សារហ៊ុន TOCOM | ៣១ |
| **ចំណេះដឹងទូទៅ** | |
| ❖ ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ (តចប់) | ៣២ |
| **ក្រាហ្វិក** | |
| ❖ ក្រាហ្វិកទី១៖ តម្លៃកៅស៊ូប្រភេទ SMR 20 ធៀបនឹងតម្លៃប្រេងឆៅរបស់ក្រុមហ៊ុន Brent | ២៩ |
| ❖ ក្រាហ្វិកទី២៖ និន្នាការតម្លៃកៅស៊ូនៅពេលអនាគត RSS3 នៅទីផ្សារ TOCOM និង លុយយ៉េនប្រទេសជប៉ុន | ៣០ |

# បទវិចារណកថា

## ប្រិយមិត្តទាំងអស់ជាទីមេត្រី!

នៅត្រឹមត្រីមាសទី១ដើមឆ្នាំ២០១៧នេះ បរិមាណផលិតផលកៅស៊ូធម្មជាតិក្នុងសមាគម ANRPC ដែលទទួលបានពីបណ្តាប្រទេសជាសមាជិក បានប៉ាន់ប្រមាណថាមានចំនួនសរុប ២,៤៩៩លានតោន គឺមានការកើនឡើង ២% ធៀបរយៈពេលដូចគ្នាទៅនឹងឆ្នាំ២០១៦។ ទន្ទឹមនឹងនេះ ការប្រើប្រាស់កៅស៊ូធម្មជាតិដោយបណ្តាប្រទេសនានាក្នុងសមាគមមានបរិមាណសរុបចំនួន ១,៩៥១លានតោន ស្មើនឹង ៧៨% នៃផលិតផលសម្រេចបាន។ ចំពោះនិន្នាការទីផ្សារកៅស៊ូធម្មជាតិវិញ បានបង្ហាញថាមានការធ្លាក់ចុះបន្តិច (ប្រមាណ២,២%) ចាប់ពីពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០១៧ ក៏ប៉ុន្តែបានបង្ហាញសញ្ញាល្អឡើងវិញហើយចាប់ពីចុងខែមីនាឆ្នាំ២០១៧។ សញ្ញាល្អនេះ គឺអាស្រ័យដោយស្ថានភាពសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកនិងតំបន់អឺរ៉ុបមានភាពកាន់តែប្រសើរឡើងបន្តិចម្តងៗ កំណើនលើសពីការរំពឹងទុកនៃការទិញ-លក់សំបកកង់យានយន្តគ្រប់ប្រភេទនៅក្នុងប្រទេសចិន និងការងើបឡើងវិញនៃតម្លៃប្រេងឆៅផងដែរ។

នៅក្នុងត្រីមាសទី២ (មេសា - មិថុនា) ឆ្នាំ២០១៧ បរិមាណផលិតផលកៅស៊ូធម្មជាតិក្នុងសមាគម ANRPC រំពឹងថានឹងកើនឡើងប្រមាណ ៥,៨% ស្មើនឹងបរិមាណសរុប ២,៤៩១លានតោន ធៀបនឹង ២,៣៥៥លានតោន នៃរយៈពេលដូចគ្នាកាលពីឆ្នាំ២០១៦ ។ ទោះជាយ៉ាងណាក៏ដោយ រហូតដល់ខែឧសភា ឆ្នាំ២០១៧ ទិន្នផលកៅស៊ូធម្មជាតិនៅតែមានផលិតភាពទាបនៅឡើយនៅស្ទើរតែគ្រប់ប្រទេស (លើកលែងតែប្រទេសឥណ្ឌូណេស៊ី) ដោយសារតែការសម្រាកចៀរជ័រក្នុងរដូវកៅស៊ូជ្រុះស្លឹក ដែលបានចាប់ផ្តើមក្នុងអំឡុងពេលខែកុម្ភៈ-មីនា ឆ្នាំ២០១៧។

ដោយឡែក ស្ថានភាពនីហរណ៍កម្មកៅស៊ូធម្មជាតិនៅកម្ពុជាវិញ បរិមាណបញ្ចេញលក់សរុបប្រចាំខែមីនា ឆ្នាំ២០១៧ មានចំនួន ៧ ៧៩៨តោន បានថយចុះបរិមាណចំនួន ៤៣០តោន (=-៥% ) ដែលមានតម្លៃលក់មធ្យម ស្មើនឹង ២០៣៤$US/តោន បានកើនតម្លៃ ១១២៧$US/តោន (=+១២៤%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦។ បើគិតក្នុងរយៈពេល៣ខែ (ត្រីមាសទី១ ឆ្នាំ២០១៧) បរិមាណបញ្ចេញលក់សរុបមានចំនួន ៣២ ៣៣៤តោន បានកើនបរិមាណចំនួន៦៩០៦តោន(=+២៧%) ដោយមានតម្លៃលក់ជាមធ្យមស្មើនឹង ១៩៨៣$US/តោន បានកើនតម្លៃ១០៩៣$US/តោន (= +១២៣%) ធៀបនឹងរយៈពេល៣ខែដូចគ្នា កាលពីឆ្នាំ២០១៦។

ចំពោះតម្រូវការកៅស៊ូធម្មជាតិវិញ ក៏ត្រូវបានគេប្រមើលឃើញថាមានសញ្ញាល្អផងដែរ ដោយផ្អែកលើការលើកលែងពន្ធរបស់សហរដ្ឋអាមេរិកទៅលើការនាំចូលសំបកកង់យានយន្តធុនធ្ងន់ពីប្រទេសចិន (យោងរបាយការណ៍របស់ ANRPC ប្រចាំខែមីនា ២០១៧) ស្ថានភាពប្រសើរឡើងនៃសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក និងតំបន់អឺរ៉ុបៗ និងតម្រូវការកៅស៊ូធម្មជាតិកាន់តែច្រើនឡើងបន្ថែមទៀត ពីបណ្តាប្រទេសនានា ដែលនៅក្រៅតំបន់របស់សមាគម ANRPC។

ស្របពេលជាមួយគ្នានេះ និន្នាការទីផ្សារនៃតម្លៃកៅស៊ូធម្មជាតិក្នុងត្រីមាសទី២ ក៏រំពឹងទុកថា នៅតែមានសញ្ញាកើនឡើង អាស្រ័យដោយៈ តុល្យភាពរវាងការផ្គត់ផ្គង់និងតម្រូវការនៃកៅស៊ូធម្មជាតិនៅក្នុងត្រីមាសទី២ ឆ្នាំ២០១៧ និងនិន្នាការនៅតែបន្តងើបឡើងនៃតម្លៃប្រេងឆៅ ក៏ដូចជាតម្លៃទំនិញគ្រប់ប្រភេទនៅលើទីផ្សារ។

ក្រុមការងាររៀបចំព្រឹត្តិបត្រកៅស៊ូធម្មជាតិនៃអគ្គនាយកដ្ឋានកៅស៊ូ នឹងនៅតែបន្តយកចិត្តទុកដាក់តាមដានពីគ្រប់មជ្ឈដ្ឋាននិងប្រភពព័ត៌មាននានា ដើម្បីផ្តល់ជូនដល់មិត្តអ្នកអាននូវខ្លឹមសារនិងរូបភាពកាន់តែច្បាស់ថែមទៀត អំពីស្ថានភាពវិវឌ្ឍន៍ និន្នាការទីផ្សារ និងទស្សនវិស័យសម្រាប់រយៈពេលខ្លី មធ្យម និងវែង នៃឧស្សាហកម្មកៅស៊ូធម្មជាតិទាំងក្នុងក្របខណ្ឌជាតិ តំបន់ និងពិភពលោក។

ជាទីបញ្ចប់ យើងខ្ញុំសង្ឃឹមថា ប្រិយមិត្តអ្នកអាននឹងស្ថិតនៅជាប់ជាមួយយើងខ្ញុំជានិច្ច និងគាំទ្រព្រឹត្តិបត្រកៅស៊ូធម្មជាតិកន្លងមក ជាពិសេស យើងខ្ញុំនៅតែទន្ទឹងរងចាំនូវការរិះគន់ដើម្បីស្ថាបនាព្រឹត្តិបត្រកៅស៊ូធម្មជាតិឲ្យកាន់តែប្រសើរប្រកបដោយគុណភាពនិងប្រសិទ្ធិភាព។ សូមអរគុណ...!

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣០ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីលើកស្ទួយឧស្សាហកម្មកៅស៊ូនាំចេញ

**<u>សម្រេច</u>**

**មាត្រា ១.-**

ត្រូវបានកែសម្រួលអត្រាអាករនាំចេញដែលគិតតាមរបៀប "ពន្ធគិតតាមឯកតា" លើមុខទំនិញជ័រកៅស៊ូ ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ដូចខាងក្រោម÷

ទំព័រ ១ នៃ ២

- ពុំជាប់អាករនាំចេញ បើតម្លៃគិតអាករនាំចេញទាបជាង ១០០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ៥០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ១០០០ ឡើងតែទាបជាង ២០០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ១០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ២០០០ ឡើងតែទាបជាង ៣០០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ២០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៣០០០ ឡើងតែទាបជាង ៤០០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ៣០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៤០០០ ដុល្លារអាមេរិកក្នុង ១ តោន ឡើងទៅ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកចាត់ចែងអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១៧ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ទំព័រ ២ នៃ ២

# ព័ត៌មានក្នុងប្រទេស

## ពិធីអបអរសាទរ ទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១០៦

នៅព្រឹកថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ នៅអគ្គនាយកដ្ឋានកៅស៊ូបានរៀបចំពិធីអបអរសាទរទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១០៦ លើប្រធានបទ «ស្ត្រីដើម្បីសុខសន្តិភាពនិងវឌ្ឍនភាព» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ និងមានវត្តមានពីលោកអគ្គនាយករង ថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និងមន្ត្រីអគ្គនាយកដ្ឋានកៅស៊ូ ជាពិសេស វត្តមានមន្ត្រីរាជការជាស្ត្រីនៃអគ្គនាយកដ្ឋានកៅស៊ូ សរុបចំនួន ៨៥ នាក់ បានអញ្ជើញចូលរួម។

ជាកិច្ចចាប់ផ្តើម លោកស្រី **យិន សុខន្ធា** ប្រធានស្ត្រីនៃអគ្គនាយកដ្ឋានកៅស៊ូ បានធ្វើរបាយការណ៍ស្តីអំពី សកម្មភាពស្ត្រីនៅអគ្គនាយកដ្ឋានកៅស៊ូ ដែលបានចូលរួមទាំងការងារក្នុងសង្គម និងអគ្គនាយកដ្ឋានកៅស៊ូផងដែរ។ ទន្ទឹមនឹងនោះ លោកស្រីក៏បានលើកឡើងពីបញ្ហាប្រឈមមួយចំនួនរួមមាន៖ (១) ទីតាំងអគ្គនាយកដ្ឋានកៅស៊ូមានចំងាយឆ្ងាយ ដែលធ្វើឲ្យមានការលំបាកក្នុងការមកបំពេញការងារប្រចាំថ្ងៃ, (២) មន្ត្រីមួយចំនួនជួបការលំបាកក្នុងជីវភាពប្រចាំថ្ងៃ, (៣) ការយល់ដឹងរបស់ស្ត្រីនៅមានកម្រិតនៅឡើយ។ ប៉ុន្តែ ការលំបាកទាំងនោះក៏ត្រូវបានជួយសម្រួល និងដោះស្រាយពីសំណាក់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូផងដែរ។



*ឯកឧត្តម **ប៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ បានអញ្ជើញជាអធិបតីភាព ក្នុងពិធីអបអរសាទរ ទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១០៦*



*ឯកឧត្តម **ប៉ុល សុផា** មានមតិសំណេះសំណាល ក្នុងអង្គពិធី*

ជាកិច្ចបន្ទាប់ ឯកឧត្តមប្រតិភូបានថ្លែងអំណរគុណនិងកោតសរសើរនូវស្មារតីខ្ពស់ចំពោះកាតព្វកិច្ច

របស់ស្ត្រី ដែលមានទំនួលខុសត្រូវ ទាំងក្នុងគ្រួសារ និងការចូលរួមសកម្មភាពការងារក្នុងសង្គម និងបានសង្កត់ធ្ងន់ថា «បើគ្មានស្ត្រីទេក្នុងគ្រួសារក៏គ្មានភាពកក់ក្តៅ បើគ្មានស្ត្រីចូលរួមការងារ ក៏គ្មានគំនិតបន្ថែមល្អៗផងដែរ ដូច្នេះ យើងត្រូវតែបន្តសកម្មភាពនេះបន្ថែមទៀត»។ ជាចុងក្រោយនៃកម្មវិធី ឯកឧត្តមប្រតិភូ ក៏បានអញ្ជើញចែកវត្ថុអនុស្សាវរីយ៍ដល់ស្ត្រីនៃអគ្គនាយកដ្ឋានកៅស៊ូ ដើម្បីលើកទឹកចិត្តសម្រាប់ការខិតខំប្រឹងប្រែងកន្លងមក។



*ឯកឧត្តម **ម៉ុល សុផា** បានអញ្ជើញចែកជូនវត្ថុអនុស្សាវរីយ៍ដល់ស្ត្រី នៃអគ្គនាយកដ្ឋានកៅស៊ូ*

## ឯកឧត្តមប្រតិភូ បានអញ្ជើញចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី «ការបើកមុខចៀរជ័រដំបូង និងបទដ្ឋានបច្ចេកទេសចៀរជ័រ» នៅខេត្តសៀមរាបនិងឧត្តរមានជ័យ

ចាប់ពីថ្ងៃទី១៥-១៦ ខែមីនា ឆ្នាំ២០១៧ ឯកឧត្តម **ម៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីអំពី «ការបើកមុខចៀរដំបូងនិងបទដ្ឋានបច្ចេកទេសចៀរជ័រ» នៅខេត្តសៀម ថ្ងៃទី១៥ ខែមីនា ដែលមានទីតាំងនៅសាលាឃុំគោកដូង ស្រុកអង្គរជុំ។

តាមរបាយការណ៍របស់លោកស្រី **សរ រ៉ានី** អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប បានឲ្យដឹងថា ផ្ទៃដីដាំដុះកៅស៊ូនៅក្នុងខេត្តសៀមរាបសរុបមានចំនួន៥២៨៨ហិកតា ដែលក្នុងនោះ៖

- ផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្ម មានចំនួន ៤ ២៧៤ហិកតា និងបានបើកមុខចៀរជ័របានចំនួន ២០០ហិកតា
- ផ្ទៃដីចម្ការកៅស៊ូគ្រួសារមានចំនួន ១០១៤ហិកតា ស្មើនឹង ៦២គ្រួសារ និងបានបើកមុខចៀរជ័របានចំនួន ៩១ហិកតា ស្មើនឹង ៨គ្រួសារ។

នៅថ្ងៃទី១៦ ខែមីនា វគ្គបណ្តុះបណ្តាលក៏ប្រារព្ធបន្តនៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តមានជ័យ។ ផ្ទៃដីកៅស៊ូដាំដុះនៃខេត្តនេះសរុបមានចំនួន ១៤ ៤៩១ ហិកតា ដែលក្នុងនោះ៖

- ផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្ម មានចំនួន ១២ ៧៨៤ហិកតា និងបានបើកមុខចៀរមានចំនួន ១ ២៦៦ហិកតា
- ផ្ទៃដីចម្ការកៅស៊ូគ្រួសារមានចំនួន ១ ៧០៧ហិកតា ស្មើនិង ១១១គ្រួសារ និងបានបើកមុខចៀរជ័របានចំនួន ២៥៦ហិកតា ស្មើនឹង ២៦គ្រួសារ។

ក្នុងឱកាសនោះដែរ ឯកឧត្តមប្រតិភូ បានមានមតិសំណេះសំណាលជាមួយនឹងកសិករកៅស៊ូគ្រួសារ ដែលបានចូលរួមក្នុងវគ្គសិក្សានេះ និងបានពន្យល់បន្ថែមលើវិស័យកៅស៊ូទាក់ទងទៅនឹងបច្ចេកទេសនៃការដាំដុះ ការថែទាំ ការព្យាបាល អត្ថប្រយោជន៍នៃការចងក្រង និងបង្កើតជាសហគមន៍កៅស៊ូគ្រួសារ ព័ត៌មានទីផ្សារក្នុងស្រុកនិងអន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាជូនកសិករ និងបានផ្តល់ឱកាសដល់កសិករលើកជាបញ្ហានិងសំណូមពរនានា ដែលកសិករកំពុងជួបប្រទះនាពេលកន្លងមក។ ជាទីបញ្ចប់ ឯកឧត្តមប្រតិភូ ក៏បានផ្តល់ជាអនុសាសន៍និងជម្រុញដល់កសិករដែលបានចូលរួមឲ្យបន្ត និងបង្កើនការដាំដុះកៅស៊ូជាបន្ថែមទៀត ក្នុងគោលបំណងបង្កើនប្រាក់ចំណូល ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រដល់កសិករនៅទីជនបទ។ បន្ទាប់មក ឯកឧត្តមប្រតិភូ ក៏បានចុះពិនិត្យផ្ទាល់ដល់ចម្ការកៅស៊ូគ្រួសារ ដើម្បីពិនិត្យអំពីស្ថានភាពទូទៅនៅចម្ការ ព្រមទាំងបានជួបម្ចាស់ចម្ការ ដោយធ្វើការណែនាំផ្ទាល់លើការថែទាំ ការដាក់ជី ការប្រមូលផល ។ល។




*ឯកឧត្តម **ប៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ បានអញ្ជើញជាអធិបតីភាព ដើម្បីបើកវគ្គបណ្តុះបណ្តាល ស្តីពី «បច្ចេកទេសបើកមុខចៀរដំបូង» ខេត្តសៀមរាប*



*ឯកឧត្តម **ប៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ បានអញ្ជើញជាអធិបតីភាព ដើម្បីបើកវគ្គបណ្តុះបណ្តាល ស្តីពី «បច្ចេកទេសបើកមុខចៀរដំបូង» ខេត្តឧត្តរមានជ័យ*



*សកម្មភាពនៃការអនុវត្តនរៀនចៀរដាក់ស្លែង*



*ការថតរូបជុំគ្នាទុកជាអនុស្សាវរីយ៍*

# វគ្គផ្សព្វផ្សាយ បច្ចេកទេស កែច្នៃជ័រកៅស៊ូសន្លឹក USS ដល់សហគមន៍កៅស៊ូ គ្រួសារ

កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូបានបើកវគ្គបណ្តុះបណ្តាលស្តីអំពី «បច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS ដល់សហគមន៍កៅស៊ូគ្រួសារ» ត្រូវបានរៀបចំ នៅស្រុកសំឡូត ខេត្តបាត់ដំបង។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណង៖

- ផ្តល់បច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS ដល់សហគមន៍កៅស៊ូគ្រួសារ
- ជំរុញការបង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូរួម នៅតាមមូលដ្ឋានរបស់ពួកគាត់។

លោក **ហ៊ឹម អួន** អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ លោក **ផន្ន សៅឫទ្ធិ** អភិបាល នៃគណៈអភិបាលស្រុកសំឡូត លោក **ឈឹម ទិជិរា** ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង បានអញ្ជើញចូលរួមជាគណៈអធិបតី និងមានកសិករកៅស៊ូគ្រួសារចូលរួមសរុបចំនួន ៥១នាក់។

ជាកិច្ចស្វាគមន៍ លោក **ផន្ន សៅឫទ្ធិ** អភិបាលស្រុកសំឡូត ក្នុងនាមអាជ្ញាធរមូលដ្ឋានបានថ្លែងអំណរគុណដល់អគ្គនាយកដ្ឋានកៅស៊ូ ដែលបានជ្រើសរើសស្រុកសំឡូត ដើម្បីបើកវគ្គផ្សព្វផ្សាយដ៏មានសារៈសំខាន់នេះ ដែលធ្វើឲ្យកសិករកៅស៊ូគ្រួសារទទួលបានចំណេះដឹងបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS និងអាចឈានទៅដល់ការបង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូរួមនាពេលខាងមុខ។

ជាកិច្ចបន្ត លោក **ឈឹម ទិជិរា** ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង បានលើកឡើងអំពីអត្ថប្រយោជន៍នៃចំណេះដឹងទៅលើខ្សែចង្វាក់នៃការកែច្នៃជ័រកៅស៊ូ។ ទោះបីបច្ចុប្បន្នតម្លៃកៅស៊ូមានភាពល្អប្រសើរបន្តិចក៏ពិតមែន ប៉ុន្តែបច្ចេកទេសការកែច្នៃវាមានសារៈសំខាន់ណាស់ ក្នុងការជួយបង្កើនតម្លៃបន្ថែម ដែលបច្ចុប្បន្នកសិករធ្វើការបង្កកទឹកជ័ររួចហើយធ្វើការលក់តែម្តងដែលធ្វើឲ្យពួកគាត់បាត់បង់តម្លៃបន្ថែម។



*លោក **ហ៊ឹម អួន** អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ បានអញ្ជើញជាអធិបតីក្នុងវគ្គផ្សព្វផ្សាយបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS ដល់សហគមន៍កៅស៊ូគ្រួសារ*

បន្ទាប់មកលោក **ហ៊ឹម អួន** អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ បានថ្លែងអំណរគុណដល់មន្ទីរកសិកម្មខេត្តនិងអាជ្ញាធរមូលដ្ឋាន ដែលបានជួយសហការនិងសម្របសម្រួល។ លើសពីនេះទៅទៀត លោកបានលើកឡើងអំពីគុណប្រយោជន៍នៃដំណាំ

កៅស៊ូដល់វគ្គផ្សព្វផ្សាយរួមមាន៖ (១)-ផ្តល់នូវប្រាក់ចំណូលអ្នកដាំកៅស៊ូ និងសេដ្ឋកិច្ចជាតិ និងបានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ (២)-បង្កើតការងារ និងមុខរបរស្ថេរភាពជូនប្រជាពលរដ្ឋនៅក្នុងតំបន់ និងជួយកាត់បន្ថយការធ្វើចំណាកស្រុក (៣)-ផ្តល់ឈើសម្រាប់ប្រើប្រាស់គ្រឿងសំណង់ សង្ហារឹមជាឈើតន្ទនៈ ដែលជួយកាត់បន្ថយការកាប់បំផ្លាញព្រៃធម្មជាតិ (៤)-ការពារការហូរច្រោះដីនិងការបង្កើតជាគម្របព្រៃបៃតងឡើងវិញ ដើម្បីជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាចំបងនាពេលបច្ចុប្បន្ន និង (៥)-តម្រូវការចាំបាច់សម្រាប់កម្មន្តសាលផលិតទំនិញឧស្សាហកម្មរាប់ពាន់មុខ។

ជាកិច្ចបញ្ចប់ លោកអគ្គនាយករង បានថ្លែងអំណរគុណដល់មន្ត្រីពាក់ព័ន្ធទាំងអស់ និងបានផ្តល់អនុសាសន៍ជូនដល់អ្នកចូលរួមទាំងអស់ ជាពិសេសកសិករកៅស៊ូគ្រួសារ ដែលមានបំណងចង់បង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូរួមត្រូវ៖ (១)-រៀបចំចងក្រងជាសហគមន៍កៅស៊ូគ្រួសារ ដើម្បីទទួលបាននូវព័ត៌មានពាក់ព័ន្ធវិស័យកៅស៊ូ និង (២)-ទំនាក់ទំនងមកអគ្គនាយកដ្ឋានកៅស៊ូ តាមរយៈជំនាញពាក់ព័ន្ធដើម្បីទទួលយកនូវសេវាបច្ចេកទេស។





*លោក **ហ៊ីម អួន** អគ្គនាយករង បានឡើងមានមតិសំណេះសំណាល*

នៅក្នុងវគ្គផ្សព្វផ្សាយនេះ ត្រូវបានលើកឡើងនូវប្រធានបទសំខាន់ៗចំនួន ២ គឺ៖

- **ការបង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូរួម**
- **បច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS**

ជាលទ្ធផល វគ្គផ្សព្វផ្សាយនេះ បានបង្ហាញឲ្យឃើញថា៖

- កសិករបានចូលរួមយ៉ាងផុសផុល និងយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការបង្ហាញអំពី បច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS និងចាប់អារម្មណ៍ជាពិសេសលើការបង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូរួម
- កសិករមានបំណងចង់បង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូរួម ប៉ុន្តែ គាត់មានការបារម្ភអំពីបញ្ហាតម្លៃ និងបញ្ហាទីផ្សារជ័រកៅស៊ូ បន្ទាប់ពី ពួកគាត់បង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូរួម
- កសិករបានសំណូពរដល់អគ្គនាយកដ្ឋានកៅស៊ូ៖ (១)-ជួយណែនាំក្នុងការសាងសង់មណ្ឌលកែច្នៃរួម និងផ្តល់សេវាបច្ចេកទេសបន្ថែម (២)-ជួយផ្តល់នូវវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសផ្សេងៗទៀតទាក់ទងនឹងការដាំដុះដំណាំកៅស៊ូ ជាពិសេសជួយរកទីផ្សារកៅស៊ូ។

# ព័ត៌មានអន្តរជាតិ

## រដ្ឋាភិបាលស្រីលង្កាសម្រេចផ្តល់ថវិកា ១,៥ពាន់លានរូពី សម្រាប់ ជួយឧបត្ថម្ភជា ជី ដល់ កសិករដាំដំណាំតែ ដូង និងកៅស៊ូគ្រួសារ

*ប្រភព៖ http://anrpc.org*
*ប្រែសម្រួលដោយលោក **កែវ សំអុន***

យោងតាមការស្នើសុំពិសេសមួយ របស់លោក Navin Dissanayake រដ្ឋមន្ត្រីក្រសួងដំណាំឧស្សាហកម្ម បានឲ្យដឹងថា ក្នុងឆ្នាំ២០១៧នេះ រដ្ឋាភិបាលប្រទេសស្រីលង្កា បានសម្រេចវិភាជថវិកាក្នុងទឹកប្រាក់ប្រមាណ ១,៥ពាន់លានរូពី សម្រាប់ជួយឧបត្ថម្ភជី ដល់កសិករដាំដំណាំតែ ដូង និងកៅស៊ូគ្រួសារ។ ថវិកានេះ គ្រោងនឹងផ្តល់ជូនស្ថាប័នពាក់ពន្ធ័រួមមាន៖ ១).អាជ្ញាធរអភិវឌ្ឍន៍ដំណាំតែខ្នាតតូចចំនួន ៩០០លានរូពី ២).ក្រុមប្រឹក្សាភិបាលដំណាំដូងចំនួន ៥០០លានរូពី និង ៣).នាយកដ្ឋានអភិវឌ្ឍន៍ដំណាំកៅស៊ូចំនួន ១០០លានរូពី។

អាជ្ញាធរពាក់ព័ន្ធ ត្រូវបានធ្វើការណែនាំដើម្បីជួយលើកិច្ចការឧបត្ថម្ភធននេះ ដល់ប្រជាកសិករឲ្យបានមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំនេះ។ ដោយឡែកម្ចាស់ចម្ការខ្នាតតូចអាចនឹងទទួលបានថវិកាឧបត្ថម្ភធនអតិបរមាប្រមាណ ១៥ ០០០រូពី/ហិកតា ក្នុងខណៈពេល ម្ចាស់ចម្ការដែលមានផ្ទៃដីទំហំប្រមាណ ១០០ម៉ែត្រ (20perch) ក៏មានសិទ្ធិទទួលបានឧបត្ថម្ភធនជាជីនេះ ផងដែរ។

ការឧបត្ថម្ភធននេះ នឹងត្រូវផ្តល់ដល់កសិករដែលមានទំហំដីអតិបរមាចំនួន២ហិកតា ក្នុងកម្រិតទឹកប្រាក់ឧបត្ថម្ភចំនួន៩០០០រូពី សម្រាប់ចម្ការដំណាំដូង និងចំនួន៥០០០រូពី សម្រាប់ចម្ការកៅស៊ូគ្រួសារ។ ការឧបត្ថម្ភធនជាជីនេះនឹងទទួលបានពីការិយាល័យប្រចាំតំបន់ ឬពីមន្ត្រីអភិវឌ្ឍន៍ដំណាំកៅស៊ូ។

## រដ្ឋ Sarawak ត្រូវរៀបចំផែនការមេ ដើម្បីពង្រឹងឧស្សាហកម្មកៅស៊ូ

*ប្រភព៖ http://anrpc.org*
*ប្រែសម្រួលដោយលោក កែវ សំអុន*

ប្រទេសម៉ាឡេស៊ី រដ្ឋ Sarawak ពិតជាត្រូវការចាំបាច់នូវផែនការមេផ្នែកឧស្សាហកម្មកៅស៊ូ ដើម្បីបំពេញតម្រូវការនៃសេដ្ឋកិច្ចមាត្រដ្ឋាន (Economic of Scale) និងសេចក្តីត្រូវការនានានៃវិស័យឧស្សាហកម្មកៅស៊ូទំនើប។

ឯកឧត្តម Douglas Uggah Embas Amar ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងទំនើបភាវូបនីយកម្មកសិកម្ម និងសេដ្ឋកិច្ចជនបទ បានថ្លែងក្នុងសន្និសីទសារព័ត៌មួយថា ក្រុមហ៊ុនផលិតសំបកកង់យានយន្តមានចំណាប់អារម្មណ៍វិនិយោគ នៅក្នុងរដ្ឋ Sarawak ប្រសិនបើរដ្ឋនេះ មានចម្ការកៅស៊ូគ្រប់គ្រាន់ ដែលមានសមត្ថភាពផ្គត់ផ្គង់វត្ថុធាតុដើមគាំទ្រដល់ឧស្សាហកម្មនេះ។

លោកអគ្គនាយក Datuk Dr Mohd Akbar Md បានលើកឡើងក្នុងអំឡុងកិច្ចប្រជុំមួយ កាលពីម្សិលមិញថា ឯកឧត្តម Douglas បានទទួលដំណឹងអំពីរឿងនេះហើយ តាមរយៈក្រុមប្រឹក្សាកៅស៊ូម៉ាឡេស៊ី។

លោកអគ្គនាយកបានបន្តថា រដ្ឋ Sarawak ចាំបាច់ត្រូវការបង្កើនវិសាលភាពផ្ទៃដីដំណាំកៅស៊ូរបស់ខ្លួន ដើម្បីបំពេញតម្រូវការឧស្សាហកម្ម ដោយសារតែបច្ចុប្បន្ន នៅទូទាំងរដ្ឋនេះមានទំហំផ្ទៃដីដាំដុះសរុបប្រមាណ១៦០ ០០០ហិកតាប៉ុណ្ណោះ ហើយឧស្សាហ-កម្មតូចមួយ នៅពេលចាប់ផ្តើមត្រូវការផ្ទៃដីយ៉ាងតិច ៣ ០០០ហិកតា ខណៈពេលដែលសិប្បកម្មផលិតស្រោមដៃខ្នាតតូចក៏មានតម្រូវការទឹកជ័រកៅស៊ូអប្បបរមា ១ ០០០តោន/ខែ ដែរ»។

លោកសង្កត់ធ្ងន់ថា «ខ្ញុំបានណែនាំដល់ក្រុមប្រឹក្សាកៅស៊ូម៉ាឡេស៊ី និងបុគ្គលិករបស់ខ្ញុំ ដើម្បីធ្វើការជិតស្និទ្ធជាមួយគ្នា ក្នុងការរៀបចំធ្វើផែនការមេមួយ សម្រាប់វិស័យឧស្សាហកម្មកៅស៊ូក្នុងរដ្ឋនេះ»។

កិច្ចខិតខំប្រឹងប្រែងនានាត្រូវតែធ្វើឡើង ដើម្បីអភិវឌ្ឍរាល់សកម្មភាពផ្នែកលំហូរខាងក្រោម នៅក្នុងឧស្សាហកម្មកៅស៊ូនេះ ដោយសារបច្ចុប្បន្ន គឺមានតែរដ្ឋ Sarawak នេះប៉ុណ្ណោះ ដែលបានកំពុងផលិតកៅស៊ូស្តង់ដាម៉ាឡេស៊ី(SMR)។ យើងមិនមានឧស្សា-ហកម្មណាមួយ ដូចជា ឧស្សាហកម្មផលិតស្រោមដៃ និងពោះវៀនកង់យានយន្តឡើយ ហើយពេលវេលាបានមកដល់សម្រាប់យើង ដើម្បីសិក្សាអំពីបញ្ហានោះឲ្យចំទិសដៅ។

ឯកឧត្តម Douglas បានឱ្យដឹងថា ក្រសួងទំនើបភាវូបនីយកម្មកសិកម្ម និងសេដ្ឋកិច្ចជនបទនឹងពិភាក្សាជាមួយក្រុមប្រឹក្សាកៅស៊ូម៉ាឡេស៊ី ថាតើត្រូវបង្កើនវិសាលភាពផ្ទៃដីដាំដុះកៅស៊ូ នៅក្នុងរដ្ឋ Sarawak យ៉ាងដូចម្តេច? ដើម្បីបំពេញតាមតម្រូវការឧស្សាហកម្ម ជាពិសេសដើម្បីគាំទ្រដល់មជ្ឈមណ្ឌលផលិតកម្មជ័រខាប់។

នៅពេលដែលមានការធានាការផ្គត់ផ្គង់កៅស៊ូជាវត្ថុធាតុដើមផលិតនោះ ពួកគេបានបង្ហើបឲ្យដឹងថា នឹងមានក្រុមហ៊ុនមួយចំនួនដែលមានការចាប់អារម្មណ៍ចូលមកវិនិយោគក្នុងរដ្ឋ Sarawak ដោយរួមទាំងលទ្ធភាពនៃការបង្កើតរោងចក្រផលិតសំបកកង់យានយន្តមួយផងដែរ។

## ក្រុមហ៊ុនសានដុងលីងឡុង សម្លឹងមើល ការជំរុញផលិតកម្មសំបកកង់យានយន្ត

*ប្រភពពី៖ http://anrpc.org*
*ប្រែសម្រួលដោយលោក **គុយ តត្តី***

លោក Wang Feng ប្រធានក្រុមហ៊ុនសានដុង លីងឡុង (Shandong Linglong Tire Co.Ltd.) បាននិយាយថា «ក្រុមហ៊ុនសំបកកង់យានយន្តនេះនឹងបោះទីតាំងផលិតកម្ម ២កន្លែងបន្ថែមទៀតនៅបរទេស ដោយប្តេជ្ញាសម្រេចឲ្យបានយ៉ាងហោចណាស់ឲ្យបាន ១ទីតាំងនៅក្នុងឆ្នាំនេះ»។

លោក Wang បាននិយាយនៅក្នុងសន្និសីទកៅស៊ូ ដែលប្រព្រឹត្តទៅនៅខេត្តក្វាងចូវ ប្រទេសចិនថា «រោងចក្ររបស់យើងនៅប្រទេសថៃកំពុងបំពេញប្រតិបត្តិការពេញសមត្ថភាព ហើយយើងគ្រោងនឹងធ្វើឲ្យសមត្ថភាពរោងចក្រនេះកាត់តែប្រសើរឡើង និងកើនឡើងពី ១០% ទៅ ២០%»។

លោកប្រធានក្រុមហ៊ុនបានបន្តថា «គម្រោងពង្រីកថ្មីនេះ នឹងបង្កើនសមត្ថភាពផលិតសំបកកង់យានយន្តសរុបរបស់ប្រទេសចិន រហូតដល់ជាង ៩០ លានគ្រាប់ក្នុងមួយឆ្នាំ»។

ក្រុមហ៊ុនលីងឡុង ដែលបានសាងសង់និងដំណើរការកាលពីឆ្នាំ២០១៥ និងមានទុនវិនិយោគចំនួន៧០០លានដុល្លារ មានសមត្ថភាពផលិតកង់រថយន្តប្រភេទទេសចរណ៍ចំនួន ១២លានគ្រាប់/ឆ្នាំ និងប្រភេទឡានដឹកទំនិញ និងឡានក្រុងចំនួន ១,២ លានគ្រាប់/ឆ្នាំ។

ក្រុមហ៊ុននេះក៏មានសាខាក្នុងស្រុកចំនួន ៣ កន្លែងរួចមកហើយ ដែលមានទីស្នាក់ការកណ្តាលស្ថិតនៅទីក្រុង Yantai ទី២ស្ថិតនៅក្រុង Dezhou និងទី៣ស្ថិតនៅក្រុង Liuzhou។

## ឥណ្ឌូនេស៊ីៈ បារាំងនឹងអភិវឌ្ឍន៍កៅស៊ូប្រកបដោយនិរន្តរភាព

*ប្រភពពី៖ http://anrpc.org*
*ប្រែសម្រួលដោយលោក **គុយ តត្តី***

ឥណ្ឌូនេស៊ីនិងបារាំងបានព្រមព្រៀងគ្នា ដើម្បីអនុវត្តកម្មវិធីសិក្សារួមគ្នាលើផ្នែកបរិស្ថាន និងសង្គម ក្នុងគោលបំណងអភិវឌ្ឍន៍ចម្ការកៅស៊ូធម្មជាតិ ប្រកបដោយនិរន្តរភាព នៅតាមបណ្តាប្រជុំកោះនានារបស់ប្រទេសឥណ្ឌូនេស៊ី។

កិច្ចព្រមព្រៀងដៃគូអភិវឌ្ឍន៍ ដែលមានទំហំទឹកប្រាក់២៧០ ០០០ដុល្លារ ត្រូវបានចុះហត្ថលេខារវាងភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និងក្រុមហ៊ុន Royal Lestari Utama (RLU) ជាក្រុមហ៊ុនមួយផ្តោតលើការអភិវឌ្ឍកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព។ កិច្ចព្រមព្រៀងនេះ ធ្វើឡើងក្នុងកំឡុងពេលទស្សនកិច្ចរបស់លោក Hollande ប្រធានាធិបតី

បារាំង នៅទីក្រុង Jakarta ប្រទេសឥណ្ឌូនេស៊ី ក្នុងសប្តាហ៍នេះ។

ក្រុមហ៊ុន RLU ដែលបានចាប់ផ្តើមកាលពីឆ្នាំ២០១៥ មានសហទុនរួមជាមួយនឹងសារជីវកម្ម Indonesian Barito Pacific Group និងក្រុមហ៊ុន Michelin (ជាក្រុមហ៊ុនផលិតសំបកកង់រថយន្តរបស់ប្រទេសបារាំង)។ ក្រុមហ៊ុនទាំងពីរបានមានគំនិតផ្តួចផ្តើមគ្រោងអភិវឌ្ឍចម្ការកៅស៊ូធម្មជាតិ ប្រកបដោយនិរន្តរភាពនិងពិពិធកម្ម និងផ្តល់លទ្ធភាពឲ្យមានការកែច្នៃនៅក្នុងតំបន់ Jambi, East Sumatra និង East Kalimantan។

យោងតាមសេចក្តីថ្លែងការណ៍របស់ លោក Andry Setiawan ប្រធានក្រុមហ៊ុន RLU បានឲ្យដឹងថា «ក្នុងនាមជាអ្នកផ្គត់ផ្គង់កៅស៊ូមួយរូប យើងប្តេជ្ញានឹងបន្តអនុវត្តការគ្រប់គ្រងកៅស៊ូ ប្រកបដោយនិរន្តរភាព ព្រមទាំង ដោះស្រាយបញ្ហាប្រឈមនានាក្នុងសង្គម និងបរិស្ថាន ដើម្បីអភិវឌ្ឍវិស័យកៅស៊ូ»។

លោក Andry បានសង្កត់បន្ថែមទៀតថា «ការរៀបចំឲ្យមានតុល្យភាពត្រឹមត្រូវរវាងសេដ្ឋកិច្ច និងបរិស្ថាន ចាំបាច់ត្រូវអភិរក្សប្រព័ន្ធជីវចម្រុះ ដើម្បីជួយសហគមន៍ឲ្យចេញពីភាពក្រីក្រ»។

លោកមានជំនឿផងដែរថា «ដៃគូអភិវឌ្ឍន៍នឹងពង្រឹងគោលនយោបាយ ដើម្បីជំរុញការគ្រប់គ្រងវិស័យកៅស៊ូឲ្យមាននិរន្តរភាព និងដោយមានការចូលរួមគាំទ្រពីសង្គម»។

RLU សង្ឃឹមថា នឹងអនុវត្តយុទ្ធសាស្រ្តទាំងនេះក្នុងតំបន់ដែលស្ថិតនៅជិត ឧទ្យានជាតិ Bukit Tigapuluh ក្នុងភាគខាងកើតតំបន់ស៊ូម៉ាត្រា ដែលកំពុងទទួលរងផលប៉ះពាល់ពីការកាប់បំផ្លាញព្រៃឈើខុសច្បាប់។

ក្រោមគំនិតផ្តួចផ្តើមរួម ដែលដឹកនាំដោយ AFD និងក្រសួងអភិវឌ្ឍន៍អន្តរជាតិ នៃប្រទេសឥណ្ឌូនេស៊ី ដៃគូអភិវឌ្ឍន៍នេះនឹងមានមូលនិធិរួមដើម្បីជំរុញកាត់បន្ថយការបំភាយឧស្ម័នកាបូន ដែលជាគម្រោងការពារបរិស្ថានក្នុងប្រទេសនេះ។

លោក Pascal Pacaut នាយកប្រតិបត្តិប្រចាំតំបន់អាស៊ី បានថ្លែងថា «យើងសង្ឃឹមថា ដៃគូអភិវឌ្ឍន៍នេះនឹងជួយ RLU ចំពោះកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រឹងការគ្រប់គ្រងបរិស្ថាន និងសង្គម ដោយផ្តល់ព័ត៌មានលម្អិតឲ្យក្រុមហ៊ុនអំពីការវាយតម្លៃលើហានិភ័យ និងឱកាសសំខាន់ៗពីខាងក្រៅ ព្រមទាំងផ្តល់អនុសាសន៍ផ្នែកយុទ្ធសាស្រ្តនិងការអនុវត្ត»។

ភាពជាដៃគូរវាង AFD និង RLU គឺជាកិច្ចព្រមព្រៀងមួយ ក្នុងចំណោមកិច្ចព្រមព្រៀងជាច្រើនទៀត ដែលបានចុះហត្ថលេខាដោយប្រទេសទាំងពីរ ក្នុងដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់លោកប្រធានាធិបតី Hollande ដែលត្រូវបានគេរំពឹងទុកថា នឹងនាំមកនូវការវិនិយោគរួម ក្នុងទឹកប្រាក់២,៦ពាន់លានដុល្លារ ដល់ប្រទេសឥណ្ឌូនេស៊ី។

# ទំព័រស្រាវជ្រាវ

## ចលនការរបស់សារធាតុគីមីដែលប្រើប្រាស់ក្នុងការកែច្នៃជ័រកៅស៊ូធម្មជាតិ
*(តចប់)*

*រៀបចំដោយ៖ នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ*

### ៣.ការបង្កកទឹកជ័រដោយប្រើប្រាស់អាស៊ីតហ្វ័រមិច (CHOOH)

ជាទូទៅ ការកែច្នៃជ័រកៅស៊ូត្រូវធ្វើការបង្កកទឹកជ័រជាមុន មុនពេលយកទៅកែច្នៃ។ មានអាស៊ីតជាច្រើនត្រូវបានប្រើប្រាស់សម្រាប់បង្កកទឹកជ័រ ក្នុងនោះ អាស៊ីតហ្វ័រមិច (CHOOH) ត្រូវបានគេជ្រើសរើសមកប្រើសម្រាប់ការបង្កក។ តាមការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា ការបង្កកទឹកជ័រកៅស៊ូធម្មជាតិដោយប្រើអាស៊ីតហ្វ័រមិចក្នុងកំហាប់សមស្របជាមួយនឹងវិធីសាស្ត្រ (method) ដែលត្រូវបានណែនាំ អាចផលិតបានជ័រកៅស៊ូស្ងួត មានគុណភាពខ្ពស់ជាមួយពណ៌ដ៏ស្រស់ស្អាត ដែលជាតម្រូវការរបស់អតិថិជន។



### ក. លក្ខណៈរបស់អាស៊ីតហ្វ័រមិច (Formic Acid)

អាស៊ីតហ្វ័រមិច ជាលក្ខណៈពាណិជ្ជកម្ម អាចរកបាននៅកំហាប់ ៨៥% និង ៩៤%។ លក្ខណៈរបស់អាស៊ីតហ្វ័រមិច រួមមាន៖ មិនមានពណ៌ រលាយបានយ៉ាងល្អនៅក្នុងទឹក មានក្លិនឆួល និងមានរសជាតិជូរ។ អាស៊ីតហ្វ័រមិច ជាអាស៊ីតខ្សោយដែលមានរូបមន្ត CHOOH វាធ្វើឲ្យតម្លៃ pH ធ្លាក់ចុះយឺតៗ ដែលជាលក្ខណៈអំណោយផលដល់ការបង្កកទឹកជ័រ ហើយវាសមស្របជាមួយនឹងបរិស្ថាន ដោយវាត្រូវការអុកស៊ីសែនក្នុងបរិមាណតិចតួច ដើម្បីបំបែកក្នុងករណីមានអាស៊ីតនៅសល់បន្ទាប់ពីការកែច្នៃ ដើម្បីកុំឲ្យមានការប៉ះពាល់ដល់បរិស្ថាន។




### ខ. អត្ថប្រយោជន៍របស់អាស៊ីតហ្វ័រមិចលើផលិតផលកៅស៊ូសន្លឹក

- ✓ ក្រោយការផលិត មិនមានសល់សំណល់អាស៊ីតនៅលើសន្លឹកជ័រកៅស៊ូ

- ✓ មិនមានផលប៉ះពាល់ទៅលើភាពយឺតរបស់កៅស៊ូ
- ✓ មិនមានផលប៉ះពាល់ទៅលើជ័រកៅស៊ូ នៅពេលដែលមានការលាយបញ្ចូលគ្នាជាមួយសារធាតុណាមួយ
- ✓ ជ័រកៅស៊ូសន្លឹកគ្មានស្នាមអុចខ្មៅ មិនស្អិត គ្មានអសុទ្ធភាព និងពពុះខ្យល់
- ✓ ចំនុចសំខាន់បំផុត ដែលអាស៊ីតហ្វ័រមិចត្រូវបានគេជ្រើសរើសមកប្រើប្រាស់ ក្នុងការផលិតជ័រកៅស៊ូ គឺវាមានភាពមិនជូរខ្លាំង និងមិនកាត់ខ្លាំង ព្រោះវាជាអាស៊ីតខ្សោយ ដែលធ្វើឲ្យមានសុវត្ថិភាពខ្ពស់នៅពេលប្រើប្រាស់(១)។

## គ. ដំណើរការបង្កករបស់អាស៊ីតហ្វ័រមិចនៅលើទឹកជ័រ

សូលុយស្យុងអាស៊ីតហ្វ័រមិច បំបែកបានជាអ៊ីយ៉ុងមេតាណូអាត ($HCOO^-$) និងអ៊ីយ៉ុងអ៊ីដ្រូសែន ($H^+$)។

$$HCOOH \rightleftharpoons HCOO^-_{(aq)} + H^+_{(aq)}$$

អ៊ីយ៉ុងអ៊ីដ្រូសែន ($H^+$) ដែលទទួលបានពីការបំបែករបស់អាស៊ីតហ្វ័រមិច ជាភ្នាក់ងារបង្កកទឹកជ័រកៅស៊ូ (latex)។ $H^+$ បានផ្តាច់សម្ព័ន្ធពីរជាន់(២) របស់កៅស៊ូធម្មជាតិឲ្យក្លាយជាទម្រង់ផ្សេងមួយទៀត (២-មេទីលប៊ុយតាន)៖




២-មេទីល ប៊ុយតាន

ក្រោយការកាត់ផ្តាច់សម្ព័ន្ធពីរជាន់ដោយ $H^+$ ទឹកជ័រចាប់ផ្តើមកកបន្តិចម្តងៗ ទៅតាមលក្ខណៈរបស់វា។




*ការបង្កកទឹកជ័រដោយសូលុយស្យុងអាស៊ីតហ្វ័រមិច*




*ប្រហែល ៦ម៉ោងក្រោយពីបង្កកទឹកជ័រ*

## ៤.សូដ្យូមមេតាប៊ីស៊ុលភីត ($Na_2S_2O_5$, ម្សៅស)

សូដ្យូមមេតាប៊ីស៊ុលភីត ឬម្សៅស ត្រូវបានអ្នកកែច្នៃមួយចំនួនប្រើប្រាស់ ក្នុងដំណាក់កាលក្រោយការបង្កកទឹកជ័រ ដើម្បីការពារផ្ទៃខាងលើនៃទឹកជ័រដែលត្រូវបង្កក មិនឲ្យរងអុកស៊ីតកម្មពីបរិយាកាស។ នៅក្នុងព្រឹត្តិបត្រកៅស៊ូធម្មជាតិ របស់អគ្គនាយកដ្ឋាន ឆ្នាំទី៥ លេខ៥០ ខែកុម្ភៈ ឆ្នាំ២០១៧ បានធ្វើការបកស្រាយអំពីតួនាទីរបស់អាម៉ូញ៉ាក់ ក្នុងការការពារអុកស៊ីកម្មពីបរិយាកាស។ ក៏ប៉ុន្តែ ក្នុងការបង្កកចាំបាច់ត្រូវធានាថានៅក្នុងទឹកជ័រមិនត្រូវមានវត្តមានអាម៉ូញ៉ាក់ ធ្វើដូចនេះគឺដើម្បីជួយកាត់បន្ថយរយៈពេលបង្កក និងការចំណាយ

បរិមាណសូលុយស្យុងអាស៊ីត។ ក្រោយពេលគ្មានវត្តមានអាម៉ូញ៉ាក់ ទឹកជ័រនឹងអាចរងអុកស៊ីតកម្មពីបរិយាកាសឡើងវិញក្នុងដំណាក់កាលកំពុង និងក្រោយបង្កក ដូចនេះ ការប្រើប្រាស់សូដ្យូមមេតាប៊ីស៊ុលហ្វីត (ម្សៅស) ជាសារធាតុការពារអុកស៊ីតកម្ម គឺត្រូវបានគេយកមកអនុវត្តន៍។

### ការបកស្រាយពីការរងអុកស៊ីតកម្មរបស់សូដ្យូមមេតាប៊ីស៊ុលហ្វីត ($Na_2S_2O_5$)៖

- ✓ សូដ្យូមមេតាប៊ីស៊ុលហ្វីត រលាយក្នុងទឹកបានសូលុយស្យុងសូដ្យូមប៊ីស៊ុលភីត ($NaHSO_3$)(៣)៖

$$Na_2S_2O_5\text{(ម្សៅ)} \xrightarrow{H_2O} NaHSO_3\text{(សូលុយស្យុង)}$$

- ✓ សូដ្យូមប៊ីស៊ុលភីត រងអុកស៊ីកម្មពីបរិយាកាស បំបែកទៅជាអំបិលសូដ្យូមស៊ុលហ្វាត ($Na_2SO_4$) ឧស្ម័នស្ព័នធ័រឌីអុកស៊ីត ($SO_2$) និងទឹក ($H_2O$)(៤)៖

$$4NaHSO_3 \xrightarrow{O_2} 2Na_2SO_4 + 2SO_2 + 2H_2O$$

$Na_2SO_4$ ៖ ជាអំបិលរលាយក្នុងទឹក

$SO_2$ ៖ ជាឧស្ម័ន

សារធាតុទាំងពីរនេះ មិនបង្កឲ្យមានផលប៉ះពាល់ដល់លក្ខណៈរបស់ជ័រកៅស៊ូទេ ព្រោះអំបិលរលាយបាត់ទៅក្នុងសូលុយស្យុង និងឧស្ម័នវាភាយបាត់ទៅក្នុងបរិយាកាស។

ដោយសារសូដ្យូមប៊ីស៊ុលភីត ជាអាស៊ីតខ្សោយនោះការប្រើប្រាស់សូដ្យូមមេតាប៊ីស៊ុលហ្វីត ត្រូវស្ថិតនៅក្នុងបទដ្ឋានដែលបានណែនាំ និងកំណត់ឲ្យប្រើប្រាស់របស់អ្នកជំនាញ (ជាមធ្យមទាបជាង ១គីឡូក្រាមក្នុងមួយតោនជ័រស្ងួត)។

### ឯកសារយោង


(១)file:///C:/Users/acer/Downloads/Documents/Brand+Formic+Acid-Brochure--Formic+acid+for+the+rubber+industry-English 2.pdf, Natural Rubber Latex coagulation using BASF Formic Acid (16/03/2017)

(២) សៀវភៅគីមីសរីរាង្គ ភាគ១, ទំព័រទី ១២៦, ២០០៣

*(៣)https://www.sigmaaldrich.com/content/dam/sigma-aldrich/docs/.../s9000pis.pdf,*Sodium bisulfite 23/03/2017

*(៤)chemiday.com/en/reaction/3-1-0-8498,***Sodium hydrosulfite react with oxygen**


# ការគ្រប់គ្រងលើការចៀរជ័រកៅស៊ូ

*រៀបចំដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ*

## ១. សេចក្តីផ្តើម

ផលិតផលសេដ្ឋកិច្ចសំខាន់របស់ដើមកៅស៊ូ គឺទឹកជ័រកៅស៊ូ (Latex) ដែលជាវត្ថុរាវដូចទឹកដោះគោមាននៅក្នុងសំបកដើមកៅស៊ូ។ ទឹកជ័រកៅស៊ូត្រូវបានប្រមូលផលតាមរយៈចៀរសំបកហៅថា «ការចៀរជ័រ»។ ការចៀរជ័រនេះពាក់ព័ន្ធទៅនឹងការបើកមុខចៀរយ៉ាងទៀងទាត់ ដោយការចៀរនូវសំបកដើមកៅស៊ូស្តើងៗយ៉ាងប្រុងប្រយ័ត្ន ដើម្បីកាត់ផ្តាច់សរសៃជ័រដែលមានផ្ទុកទឹកជ័រដោយមិនប៉ះពាល់ដល់ស្រទាប់កំប៊ីយ៉ូម (Cambium) របស់ដើមកៅស៊ូ ដែលជាអ្នកបង្កើតសំបកឡើងវិញនិងសាច់ឈើ។

ការចៀរជ័រដើមកៅស៊ូគឺជាដំណាក់កាលនៃការប្រមូលផល ហើយផ្នែកសំខាន់បំផុតរបស់ដើមកៅស៊ូ

គឺសំបក។ ការគ្រប់គ្រងសំបកកៅស៊ូដោយប្រុងប្រយ័ត្ន និងហ្មត់ចត់ក្នុងកំឡុងពេលចៀរជ័រអាចរក្សាស្ថេរភាពតម្លៃសេដ្ឋកិច្ចរបស់ចម្ការកៅស៊ូសម្រាប់រយៈពេលយ៉ាងតិច ២៥ឆ្នាំ។ ដូចនេះ អ្នកចៀរជ័រត្រូវតែទទួលការបណ្តុះបណ្តាលឲ្យបានច្បាស់លាស់។

## ២. លក្ខណៈវិនិច្ឆ័យនៃការបើកមុខចៀរដំបូង

ដើមកៅស៊ូ ដែលអាចធ្វើការបើកមុខចៀរដំបូងបានលុះត្រាតែ កម្ពស់ ១ម៉ែត្រ ពីដី ឬជើងដំរី មានរង្វង់ដើមទំហំចាប់ពី ៥០ស.ម. ឡើងទៅ និងមានចំនួនដើមយ៉ាងតិច ៧០% នៃចំនួនដើមសរុបក្នុងចម្ការ (រូបភាពទី១)។




*រូបភាពទី១ ដើមកៅស៊ូអាចចៀរជ័របាន*

## ៣ បច្ចេកទេសនៃការចៀរជ័រ

### ៣.១ ទិសនៃមុខចៀរ

ទិសរបស់សរសៃជ័រនៅក្នុងសំបកដើមកៅស៊ូ គឺជាចំនុចដ៏សំខាន់ក្នុងការបើកមុខចៀរ។ ការកាត់សរសៃជ័រដើមកៅស៊ូបានកាន់តែច្រើន នឹងទទួលបានទឹកជ័រកៅស៊ូបានកាន់តែច្រើន។ មុខចៀរដែលមានចំណោតពីស្តាំទៅឆ្វេង (A) កាត់សរសៃជ័របានតិចជាងមុខចៀរដែលមានចំណោតពីឆ្វេងទៅស្តាំ (B)។




*រូបភាពទី២ ទិសនៃការចៀរជ័រ*

## ៣.២ ចំណោតមុខចៀរ

មុំនៃចំណោតមុខចៀរ មានសារៈសំខាន់សម្រាប់ការចៀរជ័រ ដើម្បីរក្សាសំបកចៀរជ័រឲ្យបានយូរតាមដែលអាចធ្វើទៅបាន និងការពារការបាត់បង់ទឹកជ័រកៅស៊ូ (រូបភាពទី៣)។ ប៉ុន្តែប្រសិនបើចំណោតមុខចៀរទាបពេកធ្វើឲ្យទឹកជ័រហៀរចេញតាមផ្ទាំងមុខចៀរ ហើយបើមុខចៀរមានចំណោតខ្ពស់ ធ្វើឲ្យចំណែកសំបកនៅសល់ច្រើននៅពេលចៀរដល់ផ្នែកគល់ខាងក្រោម។

ដូច្នេះមុំចំណោតមុខចៀរសមស្របគឺ ៣០ដឺក្រេ ដើម្បីឲ្យទឹកជ័រហូរបានល្អ និងការពារការហូរលើផ្ទាំងមុខចៀរ (រូបភាពទី៤)។




*រូបភាពទី៣ ការបង្កើតចំណោតមុខចៀរត្រឹមត្រូវ*




*រូបភាពទី៤ ការបង្កើតមុំចំណោតត្រឹមត្រូវ*

## ៣.៣ ប្រវែងមុខចៀរ

ប្រវែងមុខចៀរ គឺជាប្រវែងសំបកដែលត្រូវចៀរក្នុងមួយពន្លាក។ ប្រវែងមុខចៀរមានទម្រង់ជាស្ពៀរ៉ាល់ (រាងជាអក្សរS)។ ប្រវែងមុខចៀរវែង (ចៀរជុំវិញដើម) អាចបន្ថយការលូតលាស់ដើមកៅស៊ូ ពីព្រោះសារធាតុចិញ្ចឹមផលិតនៅក្នុងស្លឹកមិនអាចបំលាស់ទីតាមសំបក។ ដូចនេះ ការចៀរសំបកជុំវិញដើមបង្អាក់ដល់លំហូរសារធាតុចិញ្ចឹម ដែលផ្តល់ការលូតលាស់ដល់ដើមកៅស៊ូ។

ការបើកមុខចៀរដំបូងលើកៅស៊ូត្រូវចៀរមួយភាគពីរ (ចៀរពាក់កណ្តាលជុំវិញដើម ឬ S/2 ពាក់កណ្តាលស្ពៀរ៉ាល់) នៃទំហំដើមកៅស៊ូ។ មុខចៀរវែងអាចបង្កើនទិន្នផលនៅដំណាក់កាលដំបូង ប៉ុន្តែ ទិន្នផលនឹងថយចុះបន្ទាប់ពីការចៀរជ័រ រយៈពេល២ឆ្នាំបន្ទាប់។

## ៣.៤ ចង្វាក់នៃការចៀរ

ចង្វាក់នៃការចៀរគឺជាចំនួនចៀរក្នុងមួយខ្នាតពេលនៃការចៀរជ័រលើដើមកៅស៊ូ។ ចង្វាក់នៃការចៀរជ័រដែលសមស្របបំផុតនៅកម្ពុជា គឺការចៀរ៣ថ្ងៃម្តង (d/3)។ តាមប្រព័ន្ធនេះ ចម្ការកៅស៊ូត្រូវបានបែងចែកជាបីវេន។ វេនទី១ចៀរថ្ងៃទី១ វេនទី២ ចៀរថ្ងៃទី២ ហើយវេនទី៣ ចៀរថ្ងៃទី៣ បន្ទាប់មកវិលទៅវេនទី១វិញ និងជាបន្តបន្ទាប់។ ប្រព័ន្ធនេះអាចឲ្យដើមកៅស៊ូសម្រាកបានចំនួនពីរថ្ងៃ។

ការចៀរជ័ររាល់ថ្ងៃ (d/1) មិនត្រូវបានគេណែនាំឲ្យអនុវត្តទេ ពីព្រោះវាចំណាយសំបកច្រើន ដែលប៉ះពាល់ដល់ការដុះសំបកថ្មី និងបណ្តាលឲ្យសំបកស្ងួត ដែលជាជំងឺសរីរៈហៅថាជំងឺស្ងួតមុខចៀរ (Brown blast)។

## ៤. បច្ចេកទេសនៃការបើកមុខចៀរដំបូង

### ៤.១ សម្ភារៈសម្រាប់បើកមុខចៀរ

ដើម្បីដំណើរការបើកមុខចៀរដំបូងប្រព្រឹត្តទៅបានល្អកម្មករត្រូវមាន៖

១. ម៉ែត្រសំពត់

២. ម៉ែត្រឈើប្រវែង ១.៧ម ទៅ ២ម

៣. ទង់ជ័យ Gavarite

៤. កង្វារ

៥. ពន្លាកចៀរ

៦. ថ្មសំលៀងពន្លាក

៧. ខ្សែចងកងចាន

៨. កងចាន

៩. ស្លាបព្រា

១០. ចានត្រងជ័រ

១១. ប៉ោតតូច និងធំ

១២. កន្ត្រកដាក់ជ័រចាន និងជ័រមុខ

១៣. ខ្មៅសកោស

១៤. ខ្លាញ់គោ (ប៉េត្រូឡាតូម)។

ដំបូងត្រូវវាស់ទំហំដើមដើម្បីធ្វើការជ្រើសរើសដើមកៅស៊ូ ដែលមានរង្វង់ដើម ៥០ស.ម. នៅកម្ពស់ ១ម. ពីដី និងដៅចំណាំនៅកម្ពស់ ១,៥ ម. ពីដីនូវសញ្ញា ឬចំណុចសម្គាល់ពណ៌ក្រហមលើដើម ដែលមានទំហំគ្រប់ខ្នាតសម្រាប់បើកមុខចៀរ។ បន្ទាប់មកគូសបន្ទាត់ឈរពីរឈមគ្នាតាមបណ្តោយដើម ដែលមានចំណុចក្រឹតសំគាល់នោះ ដើម្បីចែកផ្ទាំងមុខចៀរជាពីរផ្ទាំងប៉ុនគ្នា ដោយដាក់ម៉ែត្រឈើដែលមានប្រវែង២ម៉ែត្រផ្ទឹមជាប់ ហើយបញ្ឈរស្របនិងស្ថានភាពដើមឲ្យចំពាក់កណ្តាល រួចធូតឲ្យមុតជ្រៅបន្តិចតាមម៉ែត្រឈើ។ គួរកត់សម្គាល់ថា បន្ទាត់ឈរទាំងពីរមានទិសបែរទៅករងកៅស៊ូជួរមួយទៀត។

បន្ទាប់មកគេយកឧបករណ៍គំរូក្រិតមុខចៀរ (ទង់ជ័យ) ផ្ញើអំពីបន្ទះអាលុយមីញ៉ូមមកដាក់ផ្ទឹបទៅនឹងដើមកៅស៊ូត្រង់ចំណុចសម្គាល់ ១,៣ម. ពីដី រួចគូសគំនូសតាមបន្ទះអាលុយមីញ៉ូម ដើម្បីបង្កើតមុខចៀរដែលមានមុំ ៣០ដឺក្រេ។ ទន្ទឹមនឹងនេះ គេត្រូវក្រិតសំបកសម្រាប់ចៀររយៈពេល ១ខែ, ៣ខែ, ៦ខែ និងមួយឆ្នាំ។ ចំនៀរចំណាយសំបកក្នុងមួយឆ្នាំចំពោះដើមកៅស៊ូទើបបើកមុខចៀរថ្មី គឺ ១២ស.ម.។

### ៤.២ ជម្រៅមុខចៀរ

សរសៃទឹកជ័រប្រមូលផ្តុំច្រើន នៅជិតស្រទាប់កំបឹយ៉ូម (Cambium)។ ដូច្នេះដើម្បីទទួលបានទិន្នផលជ័រច្រើន គេត្រូវចៀរឲ្យបានជ្រៅដោយទុកកម្រាស់ ១ម.ម. ពីស្រទាប់កំបឹយ៉ូម (រូបភាពទី៥)។ ការចៀរប៉ះសាច់ឈើ (របួសឆ្អឹង) បណ្តាលឲ្យមានស្នាមរដិបរដុបនៅពេលសំបកដុះថ្មីឡើងវិញ ហើយវាក៏ពន្យឺតការលូតលាស់របស់ដើមកៅស៊ូផងដែរ។




*រូបភាពទី៥ ការបង្ហាញពីជម្រៅនៃការចៀរ*

### ៤.៣ ការចំណាយសំបក

ការចំណាយសំបកកំណើតត្រូវតែត្រួតពិនិត្យជាចាំបាច់ ដើម្បីឲ្យការចៀរជ័រមានរយៈពេលវែង ដែលផ្ដល់លទ្ធភាពដល់ការដុះសំបកថ្មីឡើងវិញ និងអាចត្រឡប់មកចៀរលើផ្ទាំងមុខចៀរដដែលនោះវិញបាន។ ផ្ទុយទៅវិញ វាមិនទទួលបានទឹកជ័រច្រើនទេនៅពេលដែលគេចៀរសំបកក្រាស់។ មុខចៀរ S/2 ពាក់កណ្ដាលស្ពៀរ៉ាល់ចៀររាល់បីថ្ងៃម្ដង (S/2, d3) ជាធម្មតាការចំណាយសំបកប្រចាំខែប្រហែល ១,២ស.ម. សម្រាប់សំបកកំណើត និង ១,៥ស.ម. សម្រាប់សំបកដុះថ្មី។ ដូច្នេះ ការចំណាយសំបក/ឆ្នាំ សម្រាប់សំបកកំណើតប្រហែល ១២ស.ម. និង ១៥ស.ម. សម្រាប់សំបកដុះថ្មី។

### ៤.៤ ពេលវេលានៃការចៀរជ័រ

ការចៀរជ័រត្រូវតែធ្វើនៅពេលព្រឹកព្រលឹមមុនពេលថ្ងៃរះតាមដែលអាចធ្វើទៅបាន ដើម្បីឲ្យទឹកជ័រហូរបានយូរ ពីព្រោះពេលថ្ងៃរះសម្ពាធនៅក្នុងសរសៃទឹកជ័រថយចុះ ដោយសារបំភាយនិងរំហួតទឹកក្នុងស្លឹកកៅស៊ូ ។

### ៤.៥ រានចៀរ

រានចៀរ គឺជាចំនួនដើមកៅស៊ូដែលអ្នកចៀរម្នាក់អាចចៀរបានក្នុងមួយវេន (ថ្ងៃចៀរ)។ ការកំណត់ចំនួនដើមក្នុងមួយរានចៀរ អាស្រ័យទៅលើទំហំដើម ប្រវែងមុខ ចៀរ ស្ថានភាពដី និងជួនកាលលើតម្រូវការជ័រកៅស៊ូ។

នៅលើដីរាបស្មើប្រព័ន្ធចៀរ S/2, d3 ចំនួនដើមកៅស៊ូក្នុង ១រានចៀរ មានចំនួនប្រហែល ៥០០ដើម។ នៅលើដីជម្រាលចំនួនដើមកៅស៊ូសមស្របក្នុង ១រានចៀរមានចំនួនពី ៤០០ ទៅ ៤៥០ដើម។ ក្នុងមួយរានចៀរ អ្នកចៀរជ័រប្រើពេលប្រហែល ៣ម៉ោង ហើយទុកពេលឲ្យទឹកជ័រហូរបានរយៈពេលវែងមុនធ្វើការប្រមូលទឹកជ័រ។

### ៤.៦ ល្បឿនចៀរជ័រ

ល្បឿនចៀរជ័រអាស្រ័យលើស្ថានភាពដី លក្ខខណ្ឌផ្ទាំងចៀរ ប្រព័ន្ធចៀរជ័រ កម្រាស់សំបក គម្លាតនៃចន្លោះដើម និងសុខភាពរបស់អ្នកចៀរជ័រ។

ជាធម្មតាដើមកៅស៊ូ ដែលមានរង្វង់ដើមទំហំ ៥០ស.ម. និងមានសំបករលោងដែលចៀរកន្លះស្ពៀរ៉ាល់ប្រើរយៈពេល ១០វិនាទី/ដើម។ ដូច្នេះ ដើម្បីចៀរជ័រលើដើមកៅស៊ូចំនួន ៥០០ដើម គេត្រូវប្រើរយៈពេលប្រហែល ៣ម៉ោង។

### ៤.៧ ការបំពាក់ឧបករណ៍ត្រងជ័រ

ជាធម្មតា ការចាប់ផ្ដើមបើកមុខចៀរនៅកម្ពស់ពីដី ១,៣ម៉ែត្រ។ គម្លាតពីមុខចៀរមកចានត្រងជ័រមានប្រវែង ៣៥ស.ម. ដែលក្នុងនោះគម្លាតពីមុខចៀរមកស្លាបព្រាមានប្រវែង ១៥ស.ម. និងគិតពីស្លាបព្រាមកចានត្រងជ័រមានប្រវែង ២០ស.ម.។ ដើម្បីឲ្យទឹកជ័រហូរចូលចានបានល្អ គេធូតចង្អូររាងជ្រៅបន្តិច ដូនេះទឹកជ័រហូរចុះមកក្រោមកាត់តាមស្លាបព្រា រួចស្រក់ធ្លាក់ចូលក្នុងចាន។

## ៥. ប្រព័ន្ធនៃការចៀរ

### ៥.១ ការគ្រប់គ្រងការចៀរមុខក្រោម

មុននឹងចាប់ផ្ដើមដំណើរការចៀរជ័រដំបូងគេត្រូវបើកមុខចៀរចំនួន ៣ពន្លាក ជាមុនសិន ដោយចៀរតាមលំនាំខ្នាតម៉ុចំណោតមុខចៀរ ដែលបានរៀបរាប់នៅក្នុងរបៀបបើកមុខចៀរខាងលើនិងអនុវត្តតាមជំហានដូចខាងក្រោម៖

- ✓ ពន្លាកទី១៖ ចៀរសើរៗតាមគំរូចំណោតមុខចៀរ
- ✓ ពន្លាកទី២៖ ចៀរតាមលំនាំនៃពន្លាកទី១ឲ្យបានជ្រៅជាងពន្លាកទី១បន្តិច
- ✓ ពន្លាកទី៣៖ រុញពន្លាកចៀរឲ្យបានដល់ជម្រៅតាមបទដ្ឋានដែលបានកំណត់គឺទុក១ម.ម.ពីស្រទាប់កំប៊ីយ៉ូម (Cambium)។




*រូបភាពទី៦ ការបង្ហាញពីរបៀបដាក់ចំទីតាំងផ្ទាំងមុខចៀរឲ្យបានត្រឹមត្រូវ*

## ៥.២ ការគ្រប់គ្រងការចៀរមុខលើ

ការចៀរមុខលើត្រូវបានគេប្រើ ដើម្បីទទួលបានទិន្នផលកើនច្រើនភ្លាមៗពីដើមកៅស៊ូ។ នៅកម្ពុជាការបើកមុខចៀរលើ គឺគេអនុវត្តមួយភាគបួនស្ពៀរ៉ាល់ (S/4)។

ការចៀរមុខលើចាប់ផ្តើមពីកម្ពស់នៃផ្ទាំងមុខចៀរខាងក្រោម។ ការចៀរលើផ្ទាំងចៀរត្រូវបានធ្វើឲ្យស្របនឹងទិសដូចការចៀរមុខក្រោម។ បន្ទាប់មក គេបង្កើតចង្អូរមុខចៀរចុងបញ្ចប់ ដោយគូសបញ្ឈរចង្អូរឡើងលើចំណុចកណ្តាលនៃផ្ទាំងមុខចៀរកន្លះស្ពៀរ៉ាល់ (S/2)។ បន្ទាប់មក ភ្ជាប់ចង្អូរមុខចៀរដំបូង ទៅចង្អូរមុខចៀរចុងបញ្ចប់ដោយបង្កើតចំណោត ដែលមានមុំ ៤៥ដឺក្រេ។ ចៀរ ២-៣ពន្លាក ចុះក្រោមរហូតបានទំហំមុខចៀរប៉ុននឹងផ្លែពន្លាក។ បន្ទាប់មក មុខចៀរដេញមកលើដោយបង្កើនជម្រៅចៀរជាបន្តបន្ទាប់ ដោយទុកកម្រាស់សំបកប្រមាណ ១,០-១,៥ម.ម. ពីស្រទាប់កំប៊ីយ៉ូម។




*រូបភាពទី៧ ការបង្ហាញពីរបៀបចៀរមុខលើ*

## ៥.៣ ទិស និងចំណោតមុខចៀរ

ចំពោះមុខចៀរក្រោម ចំណោតមុខចៀរ ៣០ ដឺក្រេ គឺសមស្របសម្រាប់ទឹកជ័រហូរតាមមុខចៀរដោយមិនមានការហៀរទឹកជ័រចេញពីចង្អូរមុខចៀរ។ ចំពោះមុខចៀរលើ ចំណោតមុខចៀរ ៤៥ដឺក្រេ ត្រូវបានគេណែនាំឲ្យអនុវត្ត ដើម្បីកុំឲ្យមានការហៀរទឹកជ័រចេញពីចង្អូរមុខចៀរ។

## ៥.៤ ជម្រៅនៃការចៀរ

វិធីសាស្ត្រនៃការចៀរល្អ គឺជាការចៀរមិនឲ្យប៉ះសាច់ឈើ (របួសឆ្អឹង)។ អ្នកចៀរជ័រត្រូវប្រុងប្រយ័ត្នធ្វើយ៉ាងណាកុំឲ្យមានរបួសដល់សាច់ឈើ ដើម្បីការពារជាតិទឹកដែលចេញពីសាច់ឈើមកលាយចូលជាមួយទឹកជ័រ ដែលធ្វើឲ្យទឹកជ័រមានកំហាប់ទាប និងបណ្តាលឲ្យទឹកជ័រហៀរចេញក្រៅចង្អូរ។

សំបកកំណើតនៃផ្ទាំងចៀរមុខលើ មានកម្រាស់ក្រាស់ និងមានសរសៃជ័រច្រើន ដែលតម្រូវឲ្យមានការចៀរជ្រៅជាងការចៀរមុខក្រោម តែជៀសវាងកុំឲ្យប៉ះស្រទាប់កំបឹយ៉ូម។

## ៥.៥ ការចំណាយសំបក

ការចំណាយសំបកមានភាពខុសៗគ្នាអាស្រ័យទៅលើកម្ពស់មុខចៀរ និងអាយុរបស់សំបក។ ចំពោះការចៀរមុខលើផ្ទាំងមុខចៀរដំបូងនៅទាបដែលគេអាចបកជ័រកកចេញពីមុខចៀរ ហើយការចំណាយសំបកមានប្រមាណ ២ស.ម./ខែ។ ការចៀរមុខលើកាន់តែខ្ពស់គេមិនចាំបាច់បកជ័រកកចេញឡើយ ដោយការចៀរត្រូវប្រើកម្លាំងសង្កត់ដំបូងជាការសំខាន់ ដើម្បីកាត់ជ័រកក ប៉ុន្តែ អាចនឹងចំណាយសំបកច្រើន។ ការចៀរមុខលើកាន់តែខ្ពស់ការចំណាយសំបកកាន់តែច្រើន ពីព្រោះសំបករបស់វាក្រាស់ជាងនិងរឹងជាង។ ការចំណាយសំបកនៅលើផ្ទាំងមុខចៀរលើពី ៣,៥ស.ម. - ៤ស.ម. គឺជាការធម្មតា។

## ៥.៦ ការប្រមូលទឹកជ័រ

ចំពោះការចៀរមុខលើ (upward tapping) ចង្អូរមុខចៀរត្រូវប្រើខ្សែសម្រាប់នាំទឹកជ័រហូរទៅដល់ចានទឹកជ័រ ប៉ុន្តែ វាជាការលំបាកនៅពេលមុខចៀរកាន់ខ្ពស់។ ក្នុងករណីនេះត្រូវភ្ជាប់ខ្សែនាំទឹកជ័រនៅខាងចុងនៃស្លាបព្រាដើម្បីនាំទឹកជ័រចូលក្នុងចាន។ ជម្រើសមួយទៀត គឺការប្រើស្លាបព្រាពីរភ្ជាប់ដោយខ្សែនាំទឹកជ័រ ដោយដាក់ស្លាបព្រាមួយនៅជិតមុខចៀរ និងស្លាបព្រាមួយទៀតនៅជិតចានប្រមូលទឹកជ័រ (រូបភាពទី៨)។




*រូបភាពទី៨ បម្រែបម្រួលខ្លះប្រើក្នុងការចៀរពីក្រោមទៅលើ*

## ៥.៧ ពន្លាកប្រើសម្រាប់ការចៀរ

ពន្លាកចៀរមុខលើ (upward tapping) មានផ្លែរាងអក្សរ V ។ ចំណែកឯ ពន្លាកចៀរមុខក្រោម (downward tapping) មានផ្លែរាងជាអក្សរ U ។ ពន្លាកត្រូវបានផលិតជាចង្អូរផ្ការដែលមានមុំស្រួច ដែលធ្វើឲ្យទឹកជ័រហូរជាប់បានល្អតាមចង្អូរ។ មុំសមស្របរបស់ពន្លាកផ្លែអក្សរ V គឺ ៦០ដឺក្រេ (រូបភាពទី៩)។ បើពន្លាកមានមុំតូចជាង ៦០ដឺក្រេ វាមានការពិបាកក្នុងការសំលៀង និងយកសំបកចេញពីផ្លែពន្លាក ដោយផ្លែរបស់វាមានមុំស្រួច ដែលពន្យារពេលនៃការចៀរជ័រ។




*រូបភាពទី៩ ពន្លាកផ្លែអក្សរ Vប្រើសម្រាប់ចៀរមុខលើ*

## ៦ ការគ្រប់គ្រងផ្ទាំងមុខចៀរ

ការចៀរពាក់កណ្តាលជុំស្លៀវ៉ាល់ (S/2) នៅលើផ្ទាំងមុខចៀរទី១ (BO-1) គឺត្រូវអនុវត្តន៍ចាប់ពីឆ្នាំទី១ រហូតដល់ឆ្នាំទី៦។ បន្ទាប់មក យើងចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរផ្ទាំងមុខចៀរទី១ (BO-1) ទៅផ្ទាំងមុខចៀរទី២ (BO-2) ហើយការចៀរលើផ្ទាំងមុខចៀរទី២ ត្រូវបានអនុវត្តន៍រហូតដល់ឆ្នាំទី១០ គឺចាប់ផ្តើមពីឆ្នាំទី៧-១០។ ហើយបន្តចៀរទៀតនៅឆ្នាំទី១៣ ឆ្នាំទី១៦ ឆ្នាំទី១៩ និងបញ្ចប់ក្នុងឆ្នាំទី២២។ ចំពោះការចៀរមុខលើត្រូវបានចៀរនៅក្នុងឆ្នាំទី១១ និងឆ្នាំទី១២ ហើយក៏ផ្អាកចំនួនមួយឆ្នាំសិន។ ហើយការចៀរមុខលើនឹងចាប់ផ្តើមចៀរក្នុងឆ្នាំទី១៤ និងឆ្នាំទី១៥ ហើយក៏ផ្អាកចៀរចំនួន ២ឆ្នាំទៀត និងបន្តចៀរចំនួន ២ឆ្នាំទៀត។ (ការគ្រប់គ្រងផ្ទាំងចៀរដូចរូបភាពទី១០ )

*រូបភាពទី១០ ការគ្រប់គ្រងផ្ទាំងមុខចៀរ*




## ៧ លក្ខណៈសម្បត្តិអ្នកចៀរជ័រ

អ្នកចៀរជ័រត្រូវមានភាពអំណត់ រហ័សរហួន ភាពច្បាស់លាស់ និងជំនាញ។ អ្នកចៀរជ័រត្រូវតែមានសុខភាពល្អ ដើម្បីធ្វើការងារឲ្យមានប្រសិទ្ធភាព។ ជាការប្រសើរ អ្នកចៀរជ័រគួរតែទទួលការបណ្តុះបណ្តាលដើម្បីឲ្យកសិករយល់ដឹងពីលក្ខណៈសរីរៈដើមកៅស៊ូ សារៈសំខាន់របស់សំបក និងមុខងារដែលទាក់ទងនឹងផ្នែកដទៃទៀតលើដើមកៅស៊ូ។ អ្នកចៀរជ័រត្រូវមានលក្ខណៈសម្បត្តិសំខាន់ៗដូចខាងក្រោម៖

- ✓ ចៀរឲ្យបានជ្រៅ ចៀសវាងប៉ះសាច់ឈើ (របួសឆ្អឹង)
- ✓ រក្សាចំណោតមុខចៀរឲ្យបានទៀងទាត់ ចៀសវាងហូរទឹកជ័រលើផ្ទាំងចៀរ
- ✓ ពិនិត្យការចំណាយសំបកឲ្យបានត្រឹមត្រូវ ដោយមិនលើសពីគំនូសក្រិតនៃការចំណាយសំបក
- ✓ បញ្ចប់ការចៀរជ័រតាមរានឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ដើម្បីឲ្យទឹកជ័រហូរស្រក់បានយូរមុនពេលប្រមូលទឹកជ័រ។

# និន្នាការតម្លៃនិងស្ថិតិកៅស៊ូធម្មជាតិ

## តារាងទី១៖ តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅតាមបណ្តាស្រុក ប្រចាំសប្តាហ៍ ខែមីនា ឆ្នាំ២០១៧ (រៀល/គីឡូក្រាម)

| ល.រ | ជ័រស្ងួត | | សប្តាហ៍ទី ១ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ជ័រស្ងួត | | | ជ័រកក | | |
| | | | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន(៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន(៛/គ.ក្រ) |
| ១ | លើ) | | 6.700 | 1,67 | ↓ 300 | 3.200 | 0,80 | ↓ 300 |
| ២ | ត្បូងឃ្មុំ | (មេមត់) | 6.900 | 1,72 | ↓ 100 | 3.200 | 0,80 | ↓ 200 |
| | | (អូររាំងឪ) | 6.800 | 1,70 | → 0 | 3.300 | 0,82 | → 0 |
| ៣ | កំពង់ធំ(ទំរីង) | | 7.000 | 1,75 | → 0 | 3.400 | 0,85 | → 0 |
| ៤ | រតនគិរី(អូរជុំ) | | 7.000 | 1,75 | ↓ 100 | 3.500 | 0,87 | ↓ 100 |
| | តម្លៃមធ្យម | | **6.880** | **1,72** | ↓ 100 | **3.320** | **0,83** | ↓ 120 |
| អត្រាប្តូរប្រាក់ | | | | 4.003 | | | | |

| ល.រ | ជ័រស្ងួត | | សប្តាហ៍ទី ២ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ជ័រស្ងួត | | | ជ័រកក | | |
| | | | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន(៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន(៛/គ.ក្រ) |
| ១ | លើ) | | 6.600 | 1,65 | ↓ 100 | 3.200 | 0,80 | → 0 |
| ២ | ត្បូងឃ្មុំ | (មេមត់) | 6.800 | 1,70 | ↓ 100 | 2.800 | 0,70 | ↓ 400 |
| | | (អូររាំងឪ) | 6.800 | 1,70 | → 0 | 3.300 | 0,83 | → 0 |
| ៣ | កំពង់ធំ(ទំរីង) | | 7.000 | 1,75 | → 0 | 3.400 | 0,85 | → 0 |
| ៤ | រតនគិរី(អូរជុំ) | | 6.900 | 1,73 | ↓ 100 | 3.500 | 0,88 | → 0 |
| | តម្លៃមធ្យម | | **6.820** | **1,71** | ↓ 60 | **3.240** | **0,81** | ↓ 80 |
| អត្រាប្តូរប្រាក់ | | | | 3.995 | | | | |

| ល.រ | ជ័រស្ងួត | | សប្តាហ៍ទី ៣ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ជ័រស្ងួត | | | ជ័រកក | | |
| | | | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន(៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន(៛/គ.ក្រ) |
| ១ | លើ) | | 6.600 | 1,65 | → 0 | 3.200 | 0,80 | → 0 |
| ២ | ត្បូងឃ្មុំ | (មេមត់) | 6.700 | 1,68 | ↓ 100 | 2.800 | 0,70 | → 0 |
| | | (អូររាំងឪ) | 6.800 | 1,70 | → 0 | 3.200 | 0,80 | ↓ 100 |
| ៣ | កំពង់ធំ(ទំរីង) | | 6.900 | 1,73 | ↓ 100 | 3.300 | 0,83 | ↓ 100 |
| ៤ | រតនគិរី(អូរជុំ) | | 6.900 | 1,73 | → 0 | 3.400 | 0,85 | ↓ 100 |
| | តម្លៃមធ្យម | | **6.780** | **1,70** | ↓ 40 | **3.180** | **0,80** | ↓ 60 |
| អត្រាប្តូរប្រាក់ | | | | 3.990 | | | | |

| ល.រ | ជ័រស្ងួត | | សប្តាហ៍ទី ៤ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ជ័រស្ងួត | | | ជ័រកក | | |
| | | | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន(៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន(៛/គ.ក្រ) |
| ១ | លើ) | | 6.700 | 1,67 | ↑ 100 | 3.100 | 0,77 | ↓ 100 |
| ២ | ត្បូងឃ្មុំ | (មេមត់) | 6.700 | 1,67 | → 0 | 2.800 | 0,70 | → 0 |
| | | (អូររាំងឪ) | 6.800 | 1,70 | → 0 | 3.200 | 0,80 | → 0 |
| ៣ | កំពង់ធំ(ទំរីង) | | 6.900 | 1,72 | → 0 | 3.300 | 0,82 | → 0 |
| ៤ | រតនគិរី(អូរជុំ) | | 7.000 | 1,75 | ↑ 100 | 3.400 | 0,85 | → 0 |
| | តម្លៃមធ្យម | | **6.820** | **1,70** | ↑ 40 | **3.160** | **0,79** | ↓ 20 |
| អត្រាប្តូរប្រាក់ | | | | 4.005 | | | | |

**បញ្ជាក់៖**

*ប្រភពពីអ្នកប្រមូលទិញតាមតំបន់*

*ជ័រស្ងួត: ជ័រទឹកពិតជាស្ងួត (DRC)*

*ជ័រកក: DRC ≃ 50%*

## តារាងទី២៖ តម្លៃកៅស៊ូនៅទីផ្សារប្រទេសថៃ ប្រចាំខែមីនា ឆ្នាំ២០១៧ (ឯកតា: បាត/គីឡូក្រាម)

| ថ្ងៃ | កៅស៊ូសម្ងួតឲ្យស្រពាប់ដោយខ្យល់ USS *1* | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | Hat Yai | Khlong Nga | Trang | Phuket | Surat thani | Rayong | Ubonrat chatani | មធ្យម | សន្លឹកចំហុយ | ជ័រទាន | ទឹកជ័រនៅចម្ការ |
| 1 | 76,00 | 74,00 | 74,00 | 77,00 | 77,00 | 76,00 | 76,00 | 75,71 | 81,21 | 64,00 | 75,00 |
| 2 | 75,00 | 74,00 | 75,00 | 76,00 | 76,00 | 75,00 | 75,00 | 75,14 | 80,84 | 65,00 | 76,00 |
| 3 | 76,00 | 75,00 | 75,00 | 77,00 | 77,00 | 75,00 | 76,00 | 75,86 | 81,35 | 64,00 | 76,00 |
| 6 | 77,00 | 76,00 | 77,00 | 77,00 | 77,00 | 76,00 | 76,00 | 76,57 | 82,05 | 65,00 | 77,00 |
| 7 | 76,00 | 76,00 | 75,00 | 76,00 | 76,00 | 76,00 | 75,00 | 75,71 | 81,20 | 66,00 | 78,00 |
| 8 | 73,00 | 73,00 | 74,00 | 74,00 | 74,00 | 74,00 | 74,00 | 73,71 | 79,21 | 65,00 | 74,00 |
| 9 | 73,00 | 73,00 | 73,00 | 75,00 | 75,00 | 74,00 | 74,00 | 73,86 | 79,35 | 64,00 | 72,00 |
| 10 | 73,00 | 73,00 | 73,00 | 75,00 | 75,00 | 74,00 | 74,00 | 73,86 | 79,35 | 64,00 | 72,00 |
| 13 | 73,00 | 73,00 | 72,00 | 73,00 | 73,00 | 74,00 | 74,00 | 73,14 | 78,64 | 63,00 | 68,00 |
| 14 | 74,00 | 73,00 | 72,00 | 74,00 | 74,00 | 73,00 | 73,00 | 73,29 | 78,92 | 61,00 | 67,00 |
| 15 | 73,00 | 74,00 | 73,00 | 75,00 | 75,00 | 73,00 | 73,00 | 73,71 | 79,21 | 61,00 | 66,00 |
| 16 | 73,00 | 73,00 | 72,00 | 74,00 | 74,00 | 74,00 | 74,00 | 73,43 | 78,92 | 60,00 | 67,00 |
| 17 | 73,00 | 74,00 | 74,00 | 75,00 | 75,00 | 75,00 | 75,00 | 74,43 | 79,92 | 61,00 | 69,00 |
| 21 | 73,00 | 73,00 | 72,00 | 73,00 | 73,00 | 74,00 | 74,00 | 73,14 | 78,64 | 61,00 | 70,00 |
| 22 | 71,00 | 70,00 | 70,00 | 71,00 | 71,00 | 72,00 | 72,00 | 71,00 | 76,50 | 59,00 | 72,00 |
| 23 | 70,00 | 70,00 | 70,00 | 72,00 | 72,00 | 72,00 | 72,00 | 71,14 | 76,64 | 58,00 | 69,00 |
| 24 | 70,00 | 70,00 | 69,00 | 70,00 | 70,00 | 71,00 | 70,00 | 70,00 | 75,50 | 58,00 | 68,00 |
| 27 | 67,00 | 67,00 | 65,00 | 68,00 | 68,00 | 67,00 | 68,00 | 67,14 | 72,64 | 55,00 | 66,00 |
| 28 | 66,00 | 67,00 | 65,00 | 67,00 | 68,00 | 66,00 | 66,00 | 66,43 | 71,92 | 56,00 | 65,00 |
| 29 | 68,00 | 67,00 | 68,00 | 68,00 | 69,00 | 67,00 | 67,00 | 67,71 | 73,21 | 56,00 | 64,00 |
| 30 | 68,00 | 68,00 | 68,00 | 69,00 | 69,00 | 69,00 | 69,00 | 68,57 | 74,07 | 55,00 | 62,00 |
| 31 | 69,00 | 68,00 | 69,00 | 70,00 | 70,00 | 68,00 | 69,00 | 69,00 | 74,50 | 56,00 | 65,00 |

កំណត់សំគាល់៖ នេះជាថ្លៃកៅស៊ូក្នុងស្រុកនៃប្រទេសថៃបានមកពីសមាគមន៍កៅស៊ូថៃដែលបានអង្កេតយ៉ាងតិច២-៥សមាជិក/ថ្ងៃ

*1* USS = Unsmoked Sheets (កៅស៊ូសម្ងួតឲ្យស្រពាប់ដោយខ្យល់)

## តារាងទី៣៖ តម្លៃកៅស៊ូស្តង់ដាម៉ាឡេស៊ី SMR/FOB ប្រចាំខែមីនា ឆ្នាំ២០១៧ (ដុល្លារ/តោន)

| មីនា | SMR CV | SMR L | SMR 5 | SMR GP | SMR 10 | SMR 20 |
|---|---|---|---|---|---|---|
| 1 | 2 600,00 | 2 572,50 | 2 118,50 | 2 112,00 | 2 096,00 | 2 091,50 |
| 2 | 2 600,00 | 2 571,00 | 2 106,50 | 2 100,00 | 2 084,00 | 2 079,50 |
| 3 | 2 605,50 | 2 577,00 | 2 136,00 | 2 129,00 | 2 113,00 | 2 108,50 |
| 6 | 2 617,50 | 2 583,00 | 2 180,00 | 2 173,50 | 2 157,50 | 2 152,50 |
| 7 | 2 602,00 | 2 565,50 | 2 101,50 | 2 095,00 | 2 079,00 | 2 074,00 |
| 8 | 2 587,00 | 2 547,50 | 2 026,50 | 2 020,00 | 2 004,00 | 1 999,50 |
| 9 | 2 559,50 | 2 518,50 | 2 000,50 | 1 993,50 | 1 977,50 | 1 973,50 |
| 10 | 2 568,50 | 2 546,00 | 2 038,00 | 2 031,00 | 2 015,00 | 2 010,00 |
| 13 | 2 530,00 | 2 520,50 | 2 025,50 | 2 018,50 | 2 002,50 | 1 997,50 |
| 14 | 2 542,00 | 2 507,50 | 2 041,50 | 2 034,50 | 2 018,50 | 2 014,50 |
| 15 | 2 566,00 | 2 519,00 | 2 038,00 | 2 031,50 | 2 015,50 | 2 010,50 |
| 16 | 2 574,50 | 2 536,50 | 1 999,50 | 1 992,50 | 1 976,50 | 1 971,50 |
| 17 | 2 575,00 | 2 547,00 | 2 060,50 | 2 053,50 | 2 037,50 | 2 033,50 |
| 20 | 2 575,50 | 2 549,50 | 2 079,00 | 2 072,00 | 2 056,00 | 2 052,00 |
| 21 | 2 553,00 | 2 522,00 | 2 016,50 | 2 009,50 | 1 993,50 | 1 989,50 |
| 22 | 2 533,50 | 2 491,00 | 1 932,50 | 1 925,50 | 1 909,50 | 1 905,00 |
| 23 | 2 507,00 | 2 458,50 | 1 954,50 | 1 947,50 | 1 931,50 | 1 926,50 |
| 24 | 2 484,00 | 2 435,50 | 1 929,50 | 1 922,50 | 1 906,50 | 1 902,00 |
| 27 | 2 476,00 | 2 410,50 | 1 841,50 | 1 834,50 | 1 818,50 | 1 814,00 |
| 28 | 2 482,00 | 2 413,00 | 1 883,00 | 1 876,50 | 1 860,00 | 1 855,50 |
| 29 | 2 476,00 | 2 404,50 | 1 851,50 | 1 844,50 | 1 828,50 | 1 823,50 |
| 30 | 2 458,50 | 2 382,00 | 1 805,00 | 1 798,00 | 1 782,00 | 1 777,50 |
| 31 | 2 467,50 | 2 379,50 | 1 862,00 | 1 855,00 | 1 839,00 | 1 834,50 |
| មធ្យម | *2 545,24* | *2 502,50* | *1 993,07* | *1 992,66* | *1 978,33* | *1,973,76* |
| អតិបរមា | **2 617,50** | **2 583,00** | **2 136,00** | **2 173,5** | **2 157,50** | **2 152,50** |
| អប្បបរមា | **2 458,50** | **2 379,50** | **1 805,00** | **1 798,0** | **1 782,00** | **1 777,50** |




- តម្លៃកៅស៊ូស្តង់ដាម៉ាឡេស៊ីលេខ១០ (SMR 10) បានធ្លាក់ បន្តិចនៅត្រឹម ២១៥៧,៥០ដុល្លារ/តោន ក្នុងខែមីនា ឆ្នាំ២០១៧នេះ បើធៀបទៅនឹងខែកុម្ភៈ ឆ្នាំ២០១៧ ដែលមានតម្លៃ ២៣៧៨,៥ដុល្លារ/តោន ដូចនេះសន្ទស្សន៍តម្លៃថយចុះ ១,០៩២៩ មានន័យថាតម្លៃកៅស៊ូខែកុម្ភៈ ឆ្នាំ២០១៧ បានថយចុះ ៩,២៩%។

SMR = Standard Malaysian Rubber (កៅស៊ូស្តង់ដាម៉ាឡេស៊ី), FOB = Free-on-Board (ថ្លៃទំនិញដឹកដល់កប៉ាល់)

## តារាងទី៤៖ តម្លៃកៅស៊ូធម្មជាតិចេញដោយ Association of Natural Rubber Producing Countries ប្រចាំខែមីនា ឆ្នាំ២០១៧ (ដុល្លារ/តោន)

| មីនា | Latex 60% | RSS | | TSR | |
|---|---|---|---|---|---|
| | ម៉ាឡេស៊ី(៤) | បាងកក RSS 3(២) | កូតាយ៉ាម RSS 4(៣) | បាងកក TSR 20(២) | កូឡាឡាំពួរ SMR 20(១) |
| 1 | 1 765,20 | - | 2 303,50 | - | 2 091,50 |
| 2 | 1 766,20 | - | 2 307,50 | - | 2 079,50 |
| 3 | 1 766,70 | 2 511,80 | 2 319,60 | 2 212,10 | 2 088,20 |
| 6 | 1 767,90 | 2 529,60 | 2 322,00 | 2 227,00 | 2 152,50 |
| 7 | 1 765,00 | 2 472,50 | 2 311,00 | 2 224,40 | 2 074,00 |
| 8 | 1 740,40 | 2 401,30 | 2 266,00 | 2 162,30 | 1 999,50 |
| 10 | 1 726,90 | 2 394,40 | 2 249,50 | 2 145,60 | 2 010,00 |
| 13 | 1 708,10 | 2 379,70 | 2 249,50 | 2 145,60 | 1 997,50 |
| 14 | 1 684,90 | 2 379,30 | 2 266,50 | 2 149,90 | 2 014,50 |
| 15 | 1 667,40 | 2 395,60 | 2 289,50 | 2 151,80 | 2 010,50 |
| 16 | 1 664,00 | 2 404,50 | 2 279,00 | 2 139,20 | 1 971,50 |
| 17 | 1 658,30 | 2 435,80 | 2 273,50 | 2 151,20 | 2 033,50 |
| 20 | 1 657,10 | 2 453,10 | 2 294,00 | 2 166,40 | 2 052,00 |
| 21 | 1 656,30 | 2 429,70 | 2 189,50 | 2 151,70 | 1 989,50 |
| 22 | 1 646,00 | 2 404,40 | 2 275,00 | 2 107,80 | 1 905,00 |
| 23 | 1 633,00 | 2 376,70 | 2 275,00 | 2 079,30 | 1 926,50 |
| 24 | 1 62420 | 2 359,70 | 2 276,50 | 2 048,10 | 1 902,00 |
| 27 | 1 603,90 | 2 320,60 | 2 274,00 | 2 001,50 | 1 814,00 |
| 28 | 1 599,90 | 2 356,80 | 2 258,50 | 2 005,20 | 1 855,50 |
| 29 | 1 583,10 | 2 362,20 | 2 263,00 | 1 999,90 | 1 823,50 |
| 30 | 1 562,40 | 2 334,20 | 2 264,00 | 1 986,20 | 1 777,50 |
| 31 | 1 542,60 | 2 336,70 | 2 267,00 | 1 988,40 | 1 834,50 |

**សំគាល់៖**

(១) ថ្លៃរូបវន្តផ្ទុកលើនាវាកំណត់ដោយអ្នកទិញនៅល្ងាចម៉ោង ៥:០០

(២) ថ្លៃរូបវន្តផ្ទុកលើនាវាកំណត់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូថៃ

(៣) ថ្លៃជាមធ្យមកំណត់ដោយទីផ្សារតំណ្ឌា (ដែលទាក់ទងនឹងថ្លៃទីផ្សារក្នុងស្រុក និងមិនគិតថ្លៃពន្ធ ឬថ្លៃផ្សេង)

(៤) ថ្លៃកំណត់ដោយអ្នកទិញដែលបានរាយការណ៍ជាផ្លូវការ ដោយក្រុមប្រឹក្សាកៅស៊ូម៉ាឡេស៊ី

**ពាក្យកាត់៖**

*1* TSR = Technical Specified Rubber (កៅស៊ូបញ្ជាក់គុណភាពតាមបច្ចេកទេស)

*2* RSS = Ribbed Smoked Sheets (កៅស៊ូសន្លឹកសម្ងួតដោយកំដៅនិងផ្សែង)

*3* Latex 60% (ទឹកជ័រខាប់៦០%)

*4* SMR = Standard Malaysia Rubber (កៅស៊ូស្តង់ដាប្រទេសម៉ាឡេស៊ី)

*5* STR = Standard Thai Rubber (កៅស៊ូស្តង់ដាប្រទេសថៃ)

# និន្នាការតម្លៃកៅស៊ូនិងទស្សនៈខ្លីៗ

តម្លៃកៅស៊ូធម្មជាតិបានធ្លាក់ចុះនៅតាមបណ្តាទីផ្សារកៅស៊ូធំៗ ក្នុងកំឡុងខែមីនា ឆ្នាំ២០១៧នេះ បន្ទាប់ពី មានកំណើនឡើងវិញចាប់ពីខែមករា ដល់ខែកុម្ភៈ ឆ្នាំ២០១៧នេះ។ ទីផ្សារកៅស៊ូដុំ (Block Rubber Market), ក្នុងកំឡុងខែមីនានេះ នៅកូឡាឡាំពួរ តម្លៃកៅស៊ូ SMR-20 ដែលគិតជាមធ្យមជាប្រចាំខែបានធ្លាក់ចុះ ១0%, នៅបាងកក តម្លៃកៅស៊ូ STR-20 ក៏បានធ្លាក់ចុះដែរ គឺ ១0,៩% បើប្រៀបធៀបទៅនឹងខែកុម្ភៈឆ្នាំ២០១៧។ កៅស៊ូសន្លឹក RSS-3 ដែលតម្លៃគិតជាមធ្យមប្រចាំខែ នៅបាងកក ធ្លាក់ចុះ ១២% និងកៅស៊ូសន្លឹក RSS-4 ក៏បានធ្លាក់ចុះ ៤,២% បើប្រៀបធៀបទៅនឹងខែកុម្ភៈ ឆ្នាំ២០១៧។

### តារាងទី៥៖ តម្លៃកៅស៊ូធម្មជាតិប្រចាំសប្តាហ៍ជាមធ្យម តាមបណ្តាប្រទេសផលិតកៅស៊ូ

(ដុល្លារ/តោន)

| ទីផ្សារ & ប្រភេទ | កុម្ភៈ ២០១៧ | មីនា ២០១៧ | % ប្រែប្រួល |
|---|---|---|---|
| SMR 20 (កូឡាឡាំពួរ) | 2 210 | 1 990 | -10 |
| STR 20 (បាងកក) | 2 390 | 2 130 | -10,9 |
| RSS 3 (បាងកក) | 2 750 | 2 420 | -12 |
| RSS 4 (កូតាយ៉ាម) | 2 380 | 2 280 | -4,2 |

### តារាងទី៦៖ ការនាំចេញកៅស៊ូធម្មជាតិ របស់ប្រទេសជាសមាជិកសមាគម ANRPC (000តោន)

| ប្រទេស | ២០១៥ (ពេញ១ឆ្នាំ) | មករា-មីនា ២០១៦ | មករា-មីនា២០១៧ | % ២០១៧ |
|---|---|---|---|---|
| ថៃ | 3 807 | 1 003 | 907 | 9,6 |
| ឥណ្ឌូនេស៊ី | 2 603 | 600 | 706 | 17,7 |
| វៀតណាម | 1 254 | 237 | 264 | 11,2 |
| ម៉ាឡេស៊ី | 1 053 | 250 | 266 | 6,6 |
| កម្ពុជា | 145 | 25 | 35 | 43,3 |
| ប្រទេសដ៏ទៃទៀត | 206 | 58 | 69 | 19 |
| **ANRPC** | **9 067** | **2 169** | **2 243** | **3,4** |

## ក្រាហ្វិកទី១៖ តម្លៃកៅស៊ូនៃប្រភេទ SMR 20 ធៀបនឹងតម្លៃប្រេងឆៅរបស់ក្រុមហ៊ុន Brent (២ មករា - ២៨ មីនា ២០១៧)




តម្លៃប្រេងឆៅរបស់ក្រុមហ៊ុន Brent មានផលប៉ះពាល់យ៉ាងខ្លាំង ក្នុងកំឡុងចុងខែកុម្ភៈ ឆ្នាំ២០១៧នេះ និងបានធ្លាក់ចុះក្រោមតម្លៃ ៥០ដុល្លារ ក្នុងកំឡុងពាក់កណ្តាលខែមីនានេះ ដោយសារតែកត្តានៃការកើនឡើងខ្លាំងនៃសន្និធិប្រេងឆៅ នៅសហរដ្ឋអាមេរិក និងបរាជ័យរវាងបណ្តាប្រទេសផលិតប្រេងធំៗមួយចំនួន ដើម្បីអនុវត្តន៍តាមកិច្ចព្រមព្រៀងកម្មវិធីកាត់បន្ថយការនាំចេញ។ ការធ្លាក់ចុះតម្លៃប្រេងឆៅនេះ ក៏ជះឥទ្ធិពលទៅលើតម្លៃកៅស៊ូធម្មជាតិ ដោយការប្រមើលមើលទៅលើស្ថានភាពនៃការប្រើប្រាស់កៅស៊ូសំយោគដែលបានមកពីកាកប្រេងកាត (Petroleum-devied synthetic rubber)។ យ៉ាងណាក៏ដោយ តម្លៃប្រេងឆៅក៏បានងើបឡើងវិញបន្តិចបន្តួចនៅចុងខែមីនា ដែលវាបានបង្ហាញពីភាពវិជ្ជមាននៃរំញោចទីផ្សារកៅស៊ូធម្មជាតិ។

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែមីនា ២០១៧*

# ក្រាហ្វិកទី២៖ និន្នាការតម្លៃកៅស៊ូនៅពេលអនាគត RSS 3 នៅទីផ្សារ TOCOM និង ប្រាក់យ៉េនប្រទេសជប៉ុន




សរុបរួមមក, ផលិតកម្មកៅស៊ូធម្មជាតិនៃបណ្តាជាសមាជិក ANRPC បានកើនឡើង ២% ក្នុងកំឡុងត្រីមាសទី១ ឆ្នាំ២០១៧នេះ បើគិតចាប់រយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ប៉ុន្តែ ការប្រើប្រាស់នៃបណ្តាប្រទេសជាសមាជិក ANRPC ក៏បានកើនឡើង ២,៨% ក្នុងកំឡុងពេលដដែល។ ក្នុងកំឡុងពេលត្រីមាសទី២ ឆ្នាំ២០១៧នេះ (ខែមេសា-ខែមិថុនា) ផលិតកម្មត្រូវរំពឹងថានឹងកើនឡើងដល់ ៥,៨% ពី ២,៣៥៥លានតោន ដល់ ២,៤៩១លានតោន បើធៀបទៅនឹងត្រីមាសដដែលកាលឆ្នាំមុន។ កំឡុងពេលសម្រាកចៀរបានបញ្ចប់, ការផ្គត់ផ្គង់ត្រូវបានរំពឹងថានឹងនៅតែមានកម្រិតទាបគ្រប់បណ្តាប្រទេសទាំងអស់រហូតដល់ខែឧសភា លើកលែងតែប្រទេសឥណ្ឌូនេស៊ី។

បើយើងក្រឡេកមើលផ្នែកតម្រូវការវិញ, ចក្ខុវិស័យកៅស៊ូមានភាពប្រសើរឡើង ដោយសារសហរដ្ឋអាមេរិកបានលុបចោលនូវពន្ធទំនិញនាំចូលលើផលិតផលសំបកកង់ដែលផលិតពីប្រទេសចិន។ ភាពប្រសើរឡើងនៃទស្សនៈវិស័យសេដ្ឋកិច្ចអាមេរិកនិងសហភាពអឺរ៉ុបបានឲ្យយោបល់ថា «បើមានលទ្ធភាពទៅរួច ត្រូវបង្កើនល្បឿនតម្រូវការឲ្យខ្លាំង មិនថាចំពោះកៅស៊ូធម្មជាតិដែលមិនមែនជារបស់សមាជិកបណ្តាប្រទេស ANRPC»។ ចំពោះតុល្យភាពផ្គត់ផ្គង់-តម្រូវការ ការប្រមើរមើលក្នុងត្រីមាសទី២ ឆ្នាំ២០១៧នេះ, ទីផ្សារកៅស៊ូធម្មជាតិត្រូវបានរំពឹងទុកថានឹងមានផលវិជ្ជមានពីឥទ្ធិពលនៃតម្លៃប្រេងឆៅបានប្រសើរឡើង ប្រសិនបើ OPEC កំពុងនឹងគ្រោងពង្រីងបន្ថែមលើកម្មវិធីកាត់បន្ថយការនាំចេញ ព្រមទាំងមានទំនាក់ទំនងយ៉ាងជិតស្និតលើបណ្តាប្រទេសដែលមិនមែនជាសមាជិក OPEC។

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែមីនា ២០១៧*

## តារាងទី៧៖ តម្លៃកៅស៊ូសន្លឹកលេខ៣ ( RSS3 ) នៅលើទីផ្សារហ៊ុន TOCOM

( យ៉េន/គីឡូក្រាម )

| កាលបរិច្ឆេទនៃការធ្វើពាណិជ្ជកម្ម | កិច្ចសន្យាប្រចាំខែ | | | | | |
|---|---|---|---|---|---|---|
| | មីនា ១៧ | មេសា ១៧ | ឧសភា១៧ | មិថុនា ១៧ | កក្កដា ១៧ | សីហា ១៧ |
| ១ មីនា | 304,7 | 292,4 | 286,0 | 278,8 | 273,2 | 271,8 |
| ២ មីនា | 306,0 | 295,5 | 288,5 | 283,0 | 276,9 | 274,7 |
| ៦ មីនា | 307,0 | 296,5 | 289,1 | 283,8 | 278,7 | 276,0 |
| ៧ មីនា | 305,0 | 293,5 | 284,0 | 278,0 | 272,2 | 269,4 |
| ៨ មីនា | 288,5 | 277,9 | 271,1 | 265,4 | 261,1 | 258,4 |
| ៩ មីនា | 281,1 | 275,8 | 271,4 | 266,1 | 260,0 | 257,0 |
| ១០ មីនា | 286,5 | 280,9 | 276,4 | 270,8 | 265,5 | 261,7 |
| ១៣ មីនា | 286,5 | 281,0 | 277,4 | 272,5 | 267,6 | 263,9 |
| ១៤ មីនា | 284,7 | 279,7 | 276,7 | 269,9 | 266,0 | 262,0 |
| ១៥ មីនា | 287,3 | 281,1 | 278,3 | 272,5 | 269,2 | 266,0 |
| ១៦ មីនា | 284,1 | 280,0 | 276,6 | 281,2 | 266,4 | 263,9 |
| ១៧ មីនា | 287,0 | 282,6 | 280,5 | 273,6 | 270,4 | 268,0 |
| ២១ មីនា | 287,0 | 277,0 | 275,0 | 266,3 | 264,8 | 263,0 |
| ២២ មីនា | 277,0 | 265,5 | 262,0 | 255,0 | 251,4 | 249,0 |
| ២៣ មីនា | 277,0 | 267,5 | 263,3 | 257,2 | 253,0 | 250,0 |
| ២៤ មីនា | 261,5 | 262,5 | 259,2 | 254,5 | 250,1 | 247,4 |
| ២៧ មីនា | 261,5 | 256,8 | 252,8 | 245,9 | 241,1 | 237,5 |
| ២៨ មីនា | 260,9 | 255,6 | 249,3 | 244,3 | 240,9 | 238,2 |
| ២៩ មីនា | 268.4 | 260.9 | 253.8 | 249.7 | 247.1 | 244.0 |

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែមីនា ២០១៧*

*អត្រា៖ ១ យ៉េន = 0,00៩១ដុល្លារ*

# ចំណេះដឹងទូទៅ

## ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ

## ( International Rubber Reseach and Development Board )

*( តពីលេខមុន )*

*ប្រភពពី៖ www.anrpc.org*
*ប្រែសម្រួលដោយ លោក យុន កក្កដា,*
*អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ*

### ៣- រចនាសម្ព័ន្ធដឹកនាំគ្រប់គ្រង

ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍកៅស៊ូអន្តរជាតិ "IRRDB" ដែលមានស្ថាប័នស្រាវជ្រាវចំនួន ១៩ ប្រទេសជាសមាជិក មានរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងដោយ " ក្រុមប្រឹក្សាភិបាល (Board)" ដែលមានសមាសភាព៖

១- ប្រធាន : ១រូប

២- អនុប្រធានទី១ : ១រូប

៣- អនុប្រធានទី២ : ១រូប

៤- អគ្គលេខាធិការ : ១រូប

ក្រៅពីសមាសភាពដឹកនាំខាងលើ ក្រុមប្រឹក្សា IRRDB បានបង្កើតក្រុមឯកទេស (Specialist Group) ចំនួន១០ក្រុម មានដូចខាងក្រោម៖

- ✓ ក្រុមឯកទេសផ្នែកជីវបច្ចេកវិទ្យា (Biotechnology Group)
- ✓ ក្រុមឯកទេសផ្នែកបង្កាត់ពូជរុក្ខជាតិ (Plant Breeding Group)
- ✓ ក្រុមឯកទេសផ្នែកបច្ចេកវិទ្យា និងការប្រើប្រាស់ចុងក្រោយ (Technology and End Uses Group)
- ✓ ក្រុមឯកទេសផ្នែកបរិស្ថាន (Environment Group)
- ✓ ក្រុមឯកទេសផ្នែកផ្ទេរបច្ចេកវិទ្យា (Transfer of Technology Group)
- ✓ ក្រុមឯកទេសផ្នែកសង្គម - សេដ្ឋកិច្ច (Socio - Economic Group)

- ✓ ក្រុមឯកទេសផ្នែកក្សេត្រសាស្ត្រ និងកសិរុក្ខកម្ម (Agronomy and Agroforestry Group)
- ✓ ក្រុមឯកទេសផ្នែករុក្ខវិទ្យា (Physiology Group)
- ✓ ក្រុមឯកទេសផ្នែកជំងឺរុក្ខជាតិ (Plant Pathology Group)
- ✓ ក្រុមឯកទេសផ្នែកបច្ចេកវិទ្យាប្រមូលផលទឹកជ័រ (Latex Harvesting Technology Group)

ក្រុមឯកទេសតាមផ្នែកនីមួយៗ ដឹកនាំដោយមន្ត្រីទំនាក់ទំនង (Liaison officer) ១រូប និងមានអ្នកឯកទេសមកពីគ្រប់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូនានាចូលរួមជាសមាជិក។

គណៈកម្មាធិការនាយក និងនាយកប្រតិបត្តិមានភារកិច្ចពិនិត្យនិងពិភាក្សាលើបញ្ហាបច្ចេកទេសនានា ព្រមទាំង ផ្តល់អនុសាសន៍លើបញ្ហាទាំងនោះជូនដល់ក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យនិងសម្រេច។ សកម្មភាពរបស់ IRRDB រួមមាន៖ (i)ការពិភាក្សានិងផ្លាស់ប្តូរគំនិតយោបល់រវាងវិទ្យាស្ថាននានាជាសមាជិកនៅក្នុងកិច្ចប្រជុំរបស់ខ្លួន (ii)ការត្រួតពិនិត្យសកម្មភាពនានាដែលផ្តួចផ្តើមឡើងដោយក្រុមឯកទេសជំនាញ (iii)ការផ្តល់វគ្គបណ្តុះបណ្តាលនានា និង (iv)ការរៀបចំគម្រោងស្រាវជ្រាវសំខាន់ៗ និងដាក់ឲ្យវិទ្យាស្ថានស្រាវជ្រាវជាសមាជិកយកទៅអនុវត្ត។ ជារួម ការងារភាគច្រើនរបស់ IRRDB ផ្អែកលើសកម្មភាពផ្តួចផ្តើមរបស់ក្រុមឯកទេសតាមផ្នែកនីមួយៗ ដែលមានមន្ត្រីទំនាក់ទំនង (Liaison officer) ដើរតួសម្របសម្រួលរវាងក្រុមឯកទេសនីមួយៗជាមួយលេខាធិការដ្ឋាននិងក្រុមប្រឹក្សាភិបាល។ ក្រុមឯកទេសនីមួយៗតែងជួបប្រជុំពិភាក្សាគ្នា ដើម្បីផ្លាស់ប្តូរមតិយោបល់ និងលើកសំណើនានាសម្រាប់សកម្មភាពសិក្សាស្រាវជ្រាវថ្មីៗបន្ថែមទៀត។